SME BANK

SMALL AND MEDIUM ENTERPRISE BANK OF CAMBODIA

# គម្រោងហិរញ្ញប្បទាន ប្រកបដោយលក្ខខណ្ឌអនុគ្រោះ គាំទ្រដល់វឌ្ឍនភាព នៃសហគ្រាសធុនតូច និងមធ្យម

# របាយការណ៍ប្រចាំឆ្នាំ ២០២៤

# អភិវឌ្ឍសហគ្រាសធុនតូច
# និងមធ្យម គឺបង្កើតការងារ
# អភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ
# និងប្រទេសកម្ពុជា

# #ONESME

# មាតិកា


## ០១ អំពីធនាគារ

សារពីប្រធានក្រុមប្រឹក្សាភិបាល ១
សារពីអគ្គនាយក ៣
សារតាធនាគារ ៥
ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ ៦
របាយការណ៍សម្រេចបានឆ្នាំ២០២៤ ៧
បណ្តាញសាខា ៨
វឌ្ឍនភាពនៃធនាគារ ៩
ស្ថាប័នដៃគូយុទ្ធសាស្ត្រ ១១

## ០២ លទ្ធផលអាជីវកម្ម

កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករ ទេសចរណ៍ នៅខេត្តសៀមរាប (TFSS) ១៣
គម្រោងហិរញ្ញប្បទានដោយផ្ទាល់ ១៤

## ០៣ ព្រឹត្តិការណ៍ប្រចាំឆ្នាំ

កិច្ចប្រជុំប្រចាំឆ្នាំ ១៥
កម្មវិធីបុគ្គលិកឆ្នើមប្រចាំឆ្នាំ ១៦
ព្រឹត្តិការណ៍ផ្សេងៗ ១៧
ការទទួលខុសត្រូវសង្គម ២៦
អនុស្សរណៈនៃការយោគយល់ ២៧

## ០៤

**របាយការណ៍អាជ្ញាធរ** ... ២៨

**ក្រុមប្រឹក្សាភិបាល** ... ៣០

**គណៈគ្រប់គ្រងជាន់ខ្ពស់** ... ៣៥

## ០៥

**អភិបាលកិច្ចសាជីវកម្ម** ... ៣៨

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ... ៣៩

គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម ... ៤០

គណៈកម្មការសវនកម្ម ... ៤៥

គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ ... ៤៨

## ០៦

**របាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុ ... ៥០





# #ONESME

ឆន្ទៈ និងស្មារតីជាភាតរភាពនៃគ្រួសារអេសអ៊ឹមអ៊ី, សាមគ្គីភាពជាធ្លុងមួយនៃបុគ្គលិកគ្រប់ជាន់ថ្នាក់ក្នុងការបំពេញកិច្ចការងារប្រកបដោយទំនួលខុសត្រូវ និងវិជ្ជាជីវៈ ដើម្បីសម្រេចគោលដៅរួម និងជំរុញវឌ្ឍនភាពវិស័យអេសអ៊ឹមអ៊ី នៅកម្ពុជា ”

# សារពីប្រធានក្រុមប្រឹក្សាភិបាល



“SME Bank” ប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបន្តគាំទ្រសហគ្រាសធុនតូច និងមធ្យម ស្របតាមចក្ខុវិស័យ និងបេសកម្មដែលបានដាក់ចេញ **តាមរយៈការបន្តកែលម្អ និងបន្ធូរបន្ថយលក្ខខណ្ឌឥណទាន,** បង្កើតផលិតផលថ្មីៗ និងជំរុញប្រសិទ្ធភាពនៃដំណើរការបញ្ចេញឥណទាន។

**ឯកឧត្តមបណ្ឌិត ផាន់ ផល្លា**
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន ក្រុមប្រឹក្សាភិបាល

តាងនាមក្រុមប្រឹក្សាភិបាល នៃ “SME BANK” ខ្ញុំមានកិត្តិយស និងសូមអនុញ្ញាតបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ ដែលសង្ខេបពីលទ្ធផលការងាររបស់ធនាគារ ក្នុងឆ្នាំ២០២៤។ លទ្ធផលនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដ៏មុតមាំ និងការខិតខំប្រឹងប្រែងរបស់ “SME Bank” ក្នុងនាមជាធនាគារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ដែលត្រូវបានទទួលស្គាល់ថាជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចកម្ពុជា។

ជាការពិតណាស់ ក្នុងឆ្នាំ២០២៤ កន្លងទៅ, ស្ថានភាពសេដ្ឋកិច្ចសកលនៅតែបន្តបោះជំហានទៅមុខក្នុងគន្លងនៃការងើបឡើងវិញ ប៉ុន្តែបន្តយាឃីដោយបញ្ហាប្រឈមជាច្រើន និងហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជាខ្ពស់ រួមមាន (១). បច្ច័យអវិជ្ជមានបណ្តាលមកពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន, សង្គ្រាមអ៊ីស្រាអែល-ហាម៉ាស់, ការកើនឡើងនូវគោលនយោបាយគាំពារនិយម ព្រមទាំងការបែកខ្ញែកទីតាំងភូមិសាស្ត្រសេដ្ឋកិច្ចនយោបាយ ដែលមិនត្រឹមតែបាននាំមកនូវផលវិបាកដល់ខ្សែច្រវាក់ផ្គត់ផ្គង់ និងនាំឱ្យមានការកើនឡើងថ្លៃទំនិញ, ប៉ុន្តែ ថែមទាំងបង្កើត និងបង្កើនរបាំងមកលើពាណិជ្ជកម្មអន្តរជាតិ, លំហូរទុនវិនិយោគ, លំហូរបច្ចេកវិទ្យា, លំហូរមនុស្ស និងប្រព័ន្ធទូទាត់អន្តរជាតិ និង (២). ការកើនឡើងជាញឹកញាប់នៃគ្រោះធម្មជាតិក្នុងកម្រិតធ្ងន់ធ្ងរទូទាំងសកលលោក បណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដែលបានជះឥទ្ធិពលអវិជ្ជមានមកលើដំណើរនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ក៏ដូចជាសន្តិសុខស្បៀងអាហារ។ ជាលទ្ធផល, សេដ្ឋកិច្ចសកលឆ្នាំ២០២៤ ត្រូវបានប៉ាន់ប្រមាណថាបន្តមានកំណើន ៣,២% ដែលឆ្លុះបញ្ចាំងពីការបន្តងើបឡើងវិញសន្សឹមៗនៃតម្រូវការប្រើប្រាស់ឯកជន, លំហូរវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ។

ស្ថិតក្នុងបរិការណ៍នេះ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃថានៅតែបន្តមានកំណើនល្អ ក្នុងរង្វង់ ៦,០% នាឆ្នាំ២០២៤ ដោយសារ (១). ការត្រឡប់ទៅរកភាពល្អប្រសើរឡើងវិញនៃសេដ្ឋកិច្ចសកល ជាពិសេស ប្រទេសដៃគូពាណិជ្ជកម្មកម្ពុជា និង (២). លទ្ធផលនៃការកែទម្រង់ស៊ីជម្រៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក, ការដាក់ចេញគោលនយោបាយ និងវិធានការគោលនយោបាយជំរុញកំណើនដែលបានចង្អុលបង្ហាញនិងសង្កត់ធ្ងន់បន្ថែមក្នុងក្របខណ្ឌនៃ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី១» បានហុចផលជាផ្លែផ្កា និងកាលានុវត្តភាពជាសារវន្តដល់ប្រព័ន្ធអេកូឡូស៊ីធុរកិច្ច និងពាណិជ្ជកម្ម ដែលជាមូលដ្ឋានចម្បងសម្រាប់ជំរុញជីវភាពសេដ្ឋកិច្ចជាតិ។

ទោះបីសេដ្ឋកិច្ចពិភពលោក រួមទាំងកម្ពុជា បន្តស្ថិតក្នុងភាពមិនប្រាកដប្រជា និងរងឥទ្ធិពលពីបញ្ហា សកលនានាយ៉ាងណាក៏ដោយ, វិស័យហិរញ្ញវត្ថុកម្ពុជានៅបន្តមានស្ថិរភាព និងរឹងមាំ។

ការណ៍នេះឆ្លុះបញ្ចាំងតាមរយៈ ការរក្សាបាននូវកម្រិតខ្ពស់នៃសូចនាករម៉ាក្រូប្រុងប្រយ័ត្នសំខាន់ៗ រួមមាន៖

អនុបាតសន្ទនីយភាពរបស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអនុបាតសាធនភាព សម្រាប់ធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ បើទោះបីជា ឥណទានមិនដំណើរការ (NPLS) ទាំងធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ មានការកើនឡើង ប៉ុន្តែក្នុងកម្រិតអាចគ្រប់គ្រងបាន។

ក្នុងបរិយាកាសនេះ, “SME Bank” បានបន្តបេសកកម្មយ៉ាងសកម្មក្នុងការចូលរួមជំរុញការរីកចម្រើនរបស់សហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា តាមរយៈការផ្តល់ឥណទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ។ គិតត្រឹមដំណាច់ឆ្នាំ២០២៤ នេះ “SME Bank” បានផ្តល់ឥណទាន តាមរយៈគម្រោងផ្តល់ឥណទានដោយផ្ទាល់បានចំនួន ៤៥៧ សហគ្រាស សមមូលនឹងទឹកប្រាក់សរុបចំនួន ១២២.៤ លានដុល្លារអាមេរិក ស្មើនឹងកំណើន ៤២% ធៀបនឹងឆ្នាំ២០២៣។ ក្នុងនោះ ឥណទានផ្តល់ជូនដល់វិស័យអាទិភាព (កម្មន្តសាល, ការដំឡើង, កែច្នៃ និងកសិ-ឧស្សាហកម្ម) ភ្ជាប់នឹងលក្ខខណ្ឌអនុគ្រោះខ្ពស់ សម្រេចបានប្រមាណ ៦១ ដុល្លារអាម៉េរិក ត្រូវនឹង ៥០% នៃទំហំឥណទានដោយផ្ទាល់ ខណៈទំហំឥណទានផ្តល់ជូនសហគ្រិនស្ត្រីដែលក៏ជាអាទិភាពដែរនោះសម្រេចបានប្រមាណ ៥២.២ លានដុល្លារអាម៉េរិក ស្មើនឹង ៤៣% នៃទំហំឥណទានដោយផ្ទាល់។

**“SME Bank” ប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបន្តគាំទ្រសហគ្រាសធុនតូច និងមធ្យម ស្របតាមចក្ខុវិស័យ និងបេសកកម្ម ដែលបានដាក់ចេញ តាមរយៈការបន្តកែលម្អ និងបន្ធូរបន្ថយលក្ខខណ្ឌឥណទាន, បង្កើតផលិតផលថ្មីៗ និងជំរុញប្រសិទ្ធភាពនៃដំណើរការបញ្ចេញឥណទាន។**

ចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងស្មោះស្ម័គ្រចំពោះអតិថិជនទាំងអស់ដែលតែងផ្តល់ការជឿទុកចិត្តនិងចាត់ទុកធនាគារសហគ្រាសធុនតូច និងមធ្យម ជាដៃគូដ៏ស្មោះត្រង់គាំទ្រដល់ការចាប់ផ្តើម និងការពង្រីកអាជីវកម្មទាពេលកន្លងមក។ ជាការតបស្នងដល់ទំនុកចិត្ត និងភក្តីភាព យើងខ្ញុំទាំងអស់គ្នាក្នុងនាមក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ នៃ “SME Bank” ប្តេជ្ញាបន្តប្រឹងប្រែងឆ្លើយតបនឹងតម្រូវការរបស់សហគ្រាសធុនតូច និងមធ្យម ទាំងអស់ គាំទ្រដល់វឌ្ឍនភាពនៃអាជីវកម្មក្នុងគ្រប់វិស័យ ជាពិសេសវិស័យអាទិភាព សំដៅរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឱ្យរីកចម្រើនជាលំដាប់។

# សារពីអគ្គនាយក



តាមរយៈផែនការអាជីវកម្ម ឆ្នាំ២០២៥-២០២៧, ក្នុងឆ្នាំ២០២៥ “SME Bank” បន្តផ្តោតលើការផ្តល់ឥណទានសម្រាប់វិស័យអាទិភាពដែលស្របនឹងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល **ពោលគឺផ្តោតលើកម្មន្តសាល, ការដំឡើង, កែច្នៃ និងកសិ-ឧស្សាហកម្ម។** មួយវិញទៀត “SME Bank” នឹងបង្កើនការយកចិត្តទុកដាក់លើនិរន្តភាពប្រតិបត្តិការរបស់ខ្លួន**តាមរយៈការបង្កើនប្រសិទ្ធភាពចំណាយ និងពង្រឹងគុណភាពឥណទាន។**

**លោក ជា សុភ័ក្ត**
អគ្គនាយក

ក្រោមស្លាកធនាគារគោលនយោបាយ, "SME BANK" បាន និងកំពុងបន្តខិតខំប្រឹងប្រែងឆ្លើយតប ប្រកបដោយប្រសិទ្ធភាព នឹងគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដាក់ចេញដោយ រាជរដ្ឋាភិបាលកម្ពុជា សំដៅគាំទ្រដល់ការអភិវឌ្ឍសហគ្រាស ធុនតូច និងមធ្យម នៅកម្ពុជា ជាពិសេស តាមរយៈការ ដោះស្រាយបញ្ហាប្រឈមនៃលទ្ធភាពទទួលបានឥណទានមាន លក្ខខណ្ឌអនុគ្រោះ និងអត្រាការប្រាក់សមរម្យ។ ក្នុងស្មារតីនេះ "SME BANK" បានបន្តកែលម្អលក្ខខណ្ឌតម្រូវឥណទាន លើផលិតផលមានស្រាប់ និងបញ្ចុះអត្រាការប្រាក់សម្រាប់ ឥណទានក្នុងវិស័យអាទិភាព មានជាអាទិ៍ កម្មន្តសាល និង ការកែច្នៃ។ បន្ថែមលើនេះ "SME BANK" បានវិភាគ និង ដាក់ចេញនូវវិធានការជំរុញប្រសិទ្ធភាពការងារផ្ទៃក្នុង ពោលគឺ កាត់បន្ថយពេលវេលាអនុម័តឥណទាន ដើម្បីឆ្លើយតបទៅនឹង ការចង់បានរបស់អតិថិជន។

## យុទ្ធសាស្ត្រ ឆ្នាំ២០២៤

ក្រោមផែនការអាជីវកម្ម ឆ្នាំ២០២៤-២០២៦, "SME Bank" បន្តផ្តល់អាទិភាពខ្ពស់លើការផ្តល់ឥណទាន ដោយផ្ទាល់ (DIRECT LENDING) ដល់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យកម្មន្តសាល ដំឡើង និងកែច្នៃ កសិ-ឧស្សាហកម្ម ស្របពេលដែលសហគ្រិនជាស្ត្រីក៏នៅបន្តជាអាទិភាពចម្បងសម្រាប់ "SME Bank"។ ស្របតាម ទិសដៅនេះ, "SME Bank" បានកំណត់នូវយុទ្ធសាស្ត្រជាក់លាក់មួយចំនួនសម្រាប់ឆ្នាំ ២០២៤ រួមមាន៖

- បន្តពង្រីកវិសាលភាពទីផ្សារ តាមរយៈ (១). កំណត់ បន្ថែមនូវនិយមន័យ អេស អ៊ឹម អី ផ្លឹស (SME PLUS), (២). បង្កើនទំហំឥណទានអតិបរមា ដល់ ១ លានដុល្លារអាម៉េរិក សម្រាប់សហគ្រាស ទូទៅ និង ៣ លានដុល្លារអាម៉េរិក សម្រាប់សហគ្រាសក្នុងវិស័យ ស្វាយចន្ទី, និង (៣). ដាក់ឱ្យដំណើរការនូវសាខា តាមបណ្តាខេត្ត ជាដើម។
- ជំរុញការរៀបចំបង្កើតផលិតផលថ្មីៗបន្ថែម ឆ្លើយតបនឹង តម្រូវការទីផ្សារ ដែលក្នុងនោះរាប់ទាំង "កម្មវិធី ផ្តល់កម្ចី ដោយផ្ទាល់ដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប" គ្រោងក្នុងទំហំឥណទានសរុប ៥០ លានដុល្លារអាម៉េរិក។
- បង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្ត្រផ្តល់ឥណទាន (CHANNEL STRATEGY) តាមរយៈការជំរុញយន្តការមានស្រាប់ និងគិតគូរបន្ថែម។

## លទ្ធផលប្រតិបត្តិការ ឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៤ "SME Bank" សម្រេចបាននូវលទ្ធផលចម្បងៗ មួយចំនួន រួមមាន៖

- ទ្រព្យសម្បត្តិសរុបបានកើនឡើងដល់ ៣៨០ លានដុល្លារ អាម៉េរិក ពោលគឺកើនឡើង ១៨% ធៀបនឹង ឆ្នាំ២០២៣។
- សមតុល្យឥណទានដុលសរុបសម្រេចបានប្រមាណ ២២១ លានដុល្លារអាម៉េរិក ត្រូវនឹងកំណើន ០,៤%។ ក្នុងនោះ សមតុល្យឥណទានដុលដោយផ្ទាល់មានចំនួន ១២២,៤ លានដុល្លារអាម៉េរិក កើនឡើង ៤២,១%។
- យ៉ាងណាមិញ សមតុល្យឥណទានមិនដំណើរការ (NPL) បានកើនឡើងដល់ ១៧,៦ លានដុល្លារអាម៉េរិក ស្មើនឹង ១៤,៣% នៃសមតុល្យឥណទានដុលដោយផ្ទាល់ ដែល កើនឡើង ២,៩ ពិន្ទុភាគរយ ធៀបនឹងឆ្នាំ២០២៣។
- ចំណូលសរុបសម្រេចបានប្រមាណ ១៣,៩ លានដុល្លារ អាម៉េរិក ខណៈចំណាយសរុបមានប្រមាណ ១២,៦ លាន ដុល្លារអាម៉េរិក។ ជាលទ្ធផល "SME Bank" មានផល ចំណេញប្រមាណ ១,៤ លានដុល្លារអាម៉េរិក។

## ផែនការអាជីវកម្ម ឆ្នាំ២០២៥

**តាមរយៈផែនការអាជីវកម្ម ឆ្នាំ២០២៥-២០២៧, ក្នុង ឆ្នាំ២០២៥ "SME Bank" បន្តផ្តោតលើការផ្តល់ ឥណទានសម្រាប់វិស័យអាទិភាពដែលស្របនឹងអាទិភាព គោលនយោបាយរបស់រាជរដ្ឋាភិបាលពោលគឺផ្តោតលើ កម្មន្តសាល, ការដំឡើង, កែច្នៃ និងកសិ-ឧស្សាហកម្ម។ មួយវិញទៀត "SME Bank" នឹងបង្កើនការយកចិត្ត ទុកដាក់លើនិរន្តភាពប្រតិបត្តិការរបស់ខ្លួន តាមរយៈការ បង្កើនប្រសិទ្ធភាពចំណាយនិងពង្រឹងគុណភាពឥណទាន។** ក្នុងន័យនេះ សម្រាប់ឆ្នាំ២០២៥ "SME Bank" បាន កំណត់ និងដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រជាក់លាក់ មួយចំនួន ដូចខាងក្រោម៖

- ជំរុញការគ្រប់គ្រងធនធានមនុស្សឱ្យកាន់តែប្រសើរ
- បន្តជំរុញប្រសិទ្ធភាពនៃដំណើរការអនុម័តឥណទាន
- ពិនិត្យឡើងវិញនៃលក្ខណៈសម្បត្តិនៃផលិតផលមានស្រាប់ និងបង្កើតផលិតផលថ្មីៗ
- លើកកម្ពស់ផលិតភាពការងារ ជាពិសេស ផ្នែកលក់
- លើកកម្ពស់ប្រសិទ្ធភាពចំណាយ
- ជំរុញប្រសិទ្ធភាពការគ្រប់គ្រងឥណទានមិនដំណើរការ
- សាកល្បងអនុវត្តគម្រោងធានាឥណទាន (CREDIT GUARANTEE SCHEME) និង
- ជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថល។

ចុងក្រោយ លទ្ធផលវិជ្ជមានក្នុងឆ្នាំ២០២៤ ជាពិសេស កំណើនឥណទានផ្ទាល់ បង្ហាញពីដំណើរដ៏ត្រឹមត្រូវនៃប្រតិបត្តិ ការរបស់ "SME Bank" ឆ្ពោះទៅសម្រេចបាននូវ ទស្សនវិស័យនាពេលអនាគត។ ម្យ៉ាងទៀត នេះបានឆ្លុះបញ្ចាំង ពីជំនឿទុកចិត្តរបស់សហគ្រាស និងម្ចាស់អាជីវកម្មលើសេវា របស់ "SME Bank" និងក៏ជាកម្លាំងចិត្តបន្ថែមដល់ ថ្នាក់ដឹកនាំ និងបុគ្គលិក "SME Bank" ក្នុងការបន្ត បេសកកម្មជំរុញការអភិវឌ្ឍប្រកបដោយចីរភាពរបស់សហគ្រាស ធុនតូច និងមធ្យម នៅកម្ពុជា។



# សារតាធនាគារ

សហគ្រាសធុនតូច និងមធ្យម (SMEs) ជាតួអង្គដ៏សំខាន់មួយ រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ប្រកបដោយបរិយាប័ន្ន។ សហគ្រាសធុនតូច និងមធ្យម ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ដែលបំពេញតម្រូវការមូលដ្ឋាននៃទំនិញ និងសេវាកម្ម ព្រមទាំងរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅតាមរយៈការបង្កើនប្រាក់ចំណូល និងការងារ បង្កើនផលចំណូលសរុបក្នុងស្រុក និងជំរុញការនាំចេញ។ ទោះយ៉ាងនោះក្តី ដំណើរការគ្រប់គ្រង និងអភិវឌ្ឍនៃវិស័យនេះ ប្រឈមនឹងបញ្ហាមួយចំនួន រួមមាន៖ ១-ភាពមិនទាមទារ (នៅក្រៅប្រព័ន្ធ) ២-កង្វះទុន (មូលធន) សម្រាប់ពង្រីកអាជីវកម្ម ៣-កង្វះបច្ចេកទេស និងជំនាញ។

ឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើត “SME Bank” ដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រឈមនៃកង្វះទុន។

ធនាគារទទួលបានអាជ្ញាបណ្ណផ្លូវការជាធនាគារពាណិជ្ជពីធនាគារជាតិ នៃ កម្ពុជា កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ និងស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ធនាគារ កំណត់គោលបំណង និងទិសដៅចម្បង ក្នុងការផ្តល់ហិរញ្ញប្បទានដែលមានលក្ខខណ្ឌអនុគ្រោះ (សម្បទាន) ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញ ស្របតាមគោលនយោបាយដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

វត្តមានរបស់ “SME Bank” ក្នុងរយៈពេលជិត ៥ឆ្នាំកន្លងមក ត្រូវបានទទួលស្គាល់ជា ធនាគារគោលនយោបាយនាំមុខក្នុងការផ្តល់សេវាហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមដោយផ្តោតលើវិស័យអាទិភាពរួមមាន៖

- ការផលិត និងកែច្នៃម្ហូបអាហារ ដែលជាសកម្មភាពបំប្លែងសារធាតុ ផលិតផលកសិកម្ម ឬរុក្ខជាតិ ដោយកែច្នៃទាំងស្រុង ឬកែច្នៃបឋមដោយប្រើម៉ាស៊ីន និងហត្ថកម្ម សម្រាប់មនុស្សបរិភោគ។
- កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ ផ្ទែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃ, កែច្នៃកាកសំណល់ និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍។
- ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍ គឺសំដៅលើការបង្កើត និងផ្គត់ផ្គង់សេវាបច្ចេកវិទ្យាព័ត៌មានដែលផ្សារភ្ជាប់ទៅនឹងជំនួញ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សហគ្រាសស្ថិតនៅក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសដែលអភិវឌ្ឍតំបន់នេះ (CLUSTER ZONE)។
- សហគ្រាសផលិតទំនិញវេជ្ជសាស្រ្ត និងថ្នាំពេទ្យ សំដៅលើសហគ្រាសទាំងឡាយណា ដែលផលិតឧបករណ៍ ឬគ្រឿងបរិក្ខារ និងថ្នាំពេទ្យ សម្រាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល។
- សហគ្រាសផ្តល់សេវាកម្ម គាំទ្រដល់សហគ្រាសក្នុងវិស័យអាទិភាព សំដៅដល់អាជីវកម្មដែលចែកចាយទំនិញ និងផ្តល់សេវាកម្មបម្រើដល់វិស័យអាទិភាពនានាកំណត់ដោយរាជរដ្ឋាភិបាល រួមទាំងវិស័យដែលមានសក្តានុពល និងវិស័យដែលរងផលប៉ះពាល់ខ្លាំងដោយវិបត្តិកូវីដ-១៩។

“SME Bank” បានរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាកង្វះហិរញ្ញប្បទាន ដល់សហគ្រាសធុនតូច និងមធ្យម។ បច្ចុប្បន្ន ដើម្បីសម្រេចបាននូវទិសដៅនេះ ធនាគារបាន និងកំពុងបន្តអនុវត្តគម្រោងសហហិរញ្ញប្បទានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIS) និងការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ដល់សហគ្រាសគោលដៅ និងផ្តោតសំខាន់លើការអភិវឌ្ឍផលិតផល សេវាកម្ម បន្តពង្រីកបណ្តាញចែកចាយ ក៏ដូចជាការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន។

# ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ




## ចក្ខុវិស័យ

ជាធនាគារជម្រើសដំបូង និងល្អបំផុតសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុដែលមានតម្លៃសមស្រប, ងាយស្រួលក្នុងការទទួលបានហិរញ្ញប្បទាន, ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការបម្រើសេវាកម្មល្អ។

## បេសកកម្ម

ផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## គុណតម្លៃ

យើងជឿជាក់ថា យើងអាចចូលរួមជាចំណែកមួយក្នុងការផ្តល់ជូនសេវាកម្មធនាគារដែលមានតម្លៃសមរម្យ និងប្រកបដោយគុណតម្លៃ ដើម្បីការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម ដោយផ្តល់ជូនលើសពីការរំពឹងទុកដល់បុគ្គលិក អតិថិជន និងអ្នកពាក់ព័ន្ធក្នុងអាជីវកម្មទាំងអស់។

យើងមានបំណងសម្រេចឱ្យបានតាមរយៈការអនុវត្តគុណតម្លៃរបស់យើង ដែលហៅកាត់ថា “IPACE”។

### I សុចរិតភាព

លើកកម្ពស់សុចរិតភាពក្នុងអត្តសញ្ញាណរបស់យើងដើម្បីធានាឱ្យបាននូវកេរ្តិ៍ឈ្មោះ និងទំនុកចិត្តខ្ពស់ក្នុងអាជីវកម្ម

### P បុគ្គលិក

យើងចាត់ទុកគ្រប់បុគ្គលិកជាទ្រព្យដ៏សំខាន់ហើយគោរពផ្តល់តម្លៃ និងផ្តល់ឱកាសឱ្យពួកគាត់ចូលរួមយ៉ាងសកម្មក្នុងដំណើរការអាជីវកម្មរបស់យើង

### A គណនេយ្យភាព

យើងមានទំនួលខុសត្រូវខ្ពស់ និងប្រកបដោយវិជ្ជាជីវៈចំពោះអ្នកពាក់ព័ន្ធក្នុងអាជីវកម្ម និងទៅលើតួនាទីក៏ដូចជាមុខងារដែលយើងបានកំណត់

### C អតិថិជន

ដោយសារតែអតិថិជន ជាគោលដៅចម្បង សម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់យើង នោះយើងនឹងផ្តល់ជូនសេវាកម្មដ៏ល្អឥតខ្ចោះ

### E ប្រសិទ្ធភាព

យើងខិតខំប្រឹងប្រែងសម្រាប់ប្រតិបត្តិការដ៏ល្អ ដើម្បីប្រាកដថាម្ចាស់ភាគហ៊ុនទាំងអស់ទទួលបាន ប្រាក់ចំណេញភាពរីកចម្រើន និងស្ថេរភាពអាជីវកម្ម

# របាយការណ៍សម្រេចបានឆ្នាំ២០២៤

**ចំនួនសហគ្រិន**

**+៣០៥៩ នាក់**

**ចំនួនបុគ្គលិកសរុប**

**+២១៥ នាក់**

**ចំនួនសហគ្រិនជាស្ត្រី**

**+២៨%**

**ហិរញ្ញប្បទាន វិស័យអាទិភាព**

**+៥៨%**

**សមតុល្យហិរញ្ញប្បទាន**

**+២២០ លាន ដុល្លារអាមេរិក**

**ចំនួនដៃគូសហការ**

**១៨**

**ទ្រព្យសកម្ម**

**៣៨០ លាន ដុល្លារអាមេរិក**

**ចំនួនសាខា**

**៧ សាខា**

**មូលធនធនាគារ** (លានដុល្លារអាមេរិក)

| ឆ្នាំ | មូលធន |
|---|---|
| ២០២៤ | ១៩៩ |
| ២០២៣ | ១៩៨.២ |
| ២០២២ | ១៩៨.៥ |
| ២០២១ | ១៤៨ |
| ២០២០ | ៩៩ |

**ទ្រព្យសកម្មសរុប** (លានដុល្លារអាមេរិក)

| ឆ្នាំ | ទ្រព្យសកម្ម |
|---|---|
| ២០២៤ | ៣៨០ |
| ២០២៣ | ៣២២ |
| ២០២២ | ២៨១ |
| ២០២១ | ១៥០ |
| ២០២០ | ១០០ |

# បណ្តាសាខា




## ទីស្នាក់ការកណ្តាល
អគារ "មជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច" ភូមគៀនឃ្លាំង ផ្លូវអូស៊ីអាយស៊ី ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

## សាខាផ្សារថ្មី
អគារលេខ ៣០ ផ្លូវប៉ាស្ទ័រ (៥១) កែងផ្លូវព្រៃនគរ (១២៦) សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

## សាខាខេត្តបាត់ដំបង
ផ្ទះលេខ ១៦១ និង ១៦២ ផ្លូវជាតិលេខ ៥ ក្រុមទី ៦ ភូមិរំចេក ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

## សាខាខេត្តកំពង់ស្ពឺ
ផ្លូវជាតិលេខ៤ ភូមិពាណិជ្ជកម្ម សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

## សាខាខេត្តត្បូងឃ្មុំ
ផ្លូវជាតិលេខ៧ ភូមិសួងកើត សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ

## សាខាខេត្តបន្ទាយមានជ័យ
ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

## សាខាខេត្តកំពត
ផ្លូវជាតិលេខ៣ ភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត

## សាខាខេត្តសៀមរាប
ផ្លូវលេខ ៦០ម៉ែត្រ ភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

- ទទួលបានអាជ្ញាបណ្ណជាធនាគារពាណិជ្ជ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
- ដាក់ឱ្យដំណើរការគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី ១ ជាមួយទឹកប្រាក់សរុប ១០០ លានដុល្លារអាមេរិក ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុជាដៃគូចំនួន ៣៣ និងបានបញ្ចប់ជាស្ថាពរនៅខែតុលា ឆ្នាំ២០២០
- ដាក់ឱ្យដំណើរការគម្រោងហិរញ្ញប្បទានដោយផ្ទាល់រួមមាន៖
  - → គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (CSS)
  - → គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS)
  - → គម្រោងហិរញ្ញប្បទានសម្រាប់សហគ្រិនស្ត្រី (CWES)
  - → និងគម្រោងហិរញ្ញប្បទានស្តារសហគ្រាសធុនតូច និងមធ្យម (CRSS)
- សម្រេចបាន **ទ្រព្យសកម្ម សរុបជាង ១០០ លានដុល្លារអាមេរិក**

- ទទួលបានពានរង្វាន់ជា **“ធនាគារឆ្នើមសម្រាប់ សហគ្រាសធុនតូច និងមធ្យម ប្រចាំឆ្នាំ ២០២១ នៅកម្ពុជា”** ពីស្ថាប័ន Asian Banking & Finance
- ចុះកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា, សហគ្រិនខ្មែរ, និងក្រុមហ៊ុនបញ្ញី ហ្វាញថេក ។ល។
- ដាក់ឱ្យដំណើរការគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២ ជាមួយទំហំទឹកប្រាក់សរុប ២៤០ លានដុល្លារអាមេរិកដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន ២៨ និងបានផ្តល់ហិរញ្ញប្បទានជូនដល់សហគ្រាសចំនួន ៩៨១
- សម្រេចបានទ្រព្យសកម្មសរុបជាង **១៥០ លានដុល្លារអាមេរិក**




- ដាក់ឱ្យដំណើរការគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ ជាមួយ**ទំហំទឹកប្រាក់សរុប ១៥០ លានដុល្លារអាមេរិក**ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន២៤
- បានចូលរួមជាសមាជិកសេវាទូទាត់រហ័ស (Fast Payment) របស់ធនាគារជាតិ នៃ កម្ពុជា ដើម្បីអនុញ្ញាតឱ្យអតិថិជនអាចផ្ទេរប្រាក់ឆ្លងធនាគារបានលឿនទាន់ចិត្ត
- ដាក់ឱ្យដំណើរការគម្រោងហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច ដែលជាគម្រោងហិរញ្ញប្បទានគ្មានទ្រព្យធានា (CMES)

- ដាក់ឱ្យដំណើរការសាខាថ្មីចំនួន ២ បន្ថែមទៀត រួមមានសាខាផ្សារថ្មី និងសាខាខេត្តបាត់ដំបង
- បានអភិវឌ្ឍដៃគូអាជីវកម្មជាមួយនឹងសមាគមសហគ្រាសធុនតូច និងមធ្យម ចំនួន ៥ បន្ថែម ដើម្បីជំរុញការបញ្ចេញឥណទានដោយផ្ទាល់ ទៅអតិថិជនគោលដៅ រួមមាន ស៊ីអ៊ីអូ ម៉ាស្ទ័រក្លឹប នៃក្រុមហ៊ុន ឡាយហ្វ៍ អេឌ្យូខេសិន ឯ.ក , សមាគមសហគ្រិនវ័យក្មេងកម្ពុជា, ក្រុមហ៊ុនអាហ្វ្រីប៊ី(ខេមបូឌា), សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា, និងសមាគមអ្នកផលិតចំណីអាហារកម្ពុជា
- សម្រេចបាន**ទ្រព្យសកម្មសរុបជាង ២៨១ លានដុល្លារអាមេរិក**

# វឌ្ឍនភាពនៃធនាគារ




- ដាក់ឱ្យដំណើរការសាខាថ្មីចំនួន ៤ បន្ថែមទៀត សាខាខេត្តត្បូងឃ្មុំ សាខាខេត្តកំពត សាខាខេត្តបន្ទាយមានជ័យ និងសាខាខេត្តកំពង់ស្ពឺ
- បានអភិវឌ្ឍដៃគូអាជីវកម្ម ២ បន្ថែម ដើម្បីជំរុញការបញ្ចេញឥណទានដោយផ្ទាល់ ទៅអតិថិជនគោលដៅរួមមានសមាគមស្វាយចន្ទីកម្ពុជា និងសហព័ន្ធស្វាយចន្ទីកម្ពុជា
- ចុះកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន ទ្រូម៉ាន់នី (ខេមបូឌា), ធនាគារ អេស៊ីលីដា, និងធនាគារ វឌ្ឍនៈ អាស៊ីចំកាត់  លើសេវាកម្មទូទាត់ការសងត្រឡប់ប្រាក់កម្ចីពីអតិថិជន របស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា
- ចុះកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកធនាគារ ទាក់ទងនឹងបច្ចេកទេសវិភាគឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម
- ដាក់ឱ្យដំណើរការ កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍ នៅខេត្តសៀមរាប  (Tourism Financing Scheme for Siem Reap - TFSS) ជាមួយនឹងកញ្ចប់ថវិកាចំនួន ៥០ លានដុល្លារអាមេរិក
- សម្រេចបាន**ទ្រព្យសកម្មសរុបជាង ៣២២ លានដុល្លារអាមេរិក**

- ដាក់ឱ្យដំណើរការសាខាថ្មីចំនួន ១ បន្ថែមទៀត **នៅខេត្តសៀមរាប**
- បានអភិវឌ្ឍដៃគូអាជីវកម្ម ចំនួន៤ បន្ថែម រួមមាន សភាពាណិជ្ជកម្មកម្ពុជា អង្គការ វ៉ើដុតអក់, អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម, សិប្បកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសាជីវកម្មធានាឥណទាន កម្ពុជា។
- បានផ្តួចផ្តើម   និងកំពុងដាក់ឱ្យដំណើរការ គម្រោងហិរញ្ញប្បទានសម្រាប់ប្រតិបត្តិករទឹកស្អាតកម្ពុជា ដល់ម្ចាស់សហគ្រាស ដែលជាប្រតិបត្តិករទឹកស្អាត ប្រកបដោយលក្ខខណ្ឌអនុគ្រោះ
- សម្រេចបាន **ទ្រព្យសកម្មសរុបជាង  ៣៨០ លានដុល្លារអាមេរិក**



# ស្ថាប័នដៃគូយុទ្ធសាស្ត្រ

"SME Bank" បានសហការជាមួយសមាគម និងស្ថាប័នជាច្រើន ក្នុងគោលបំណងចូលរួមលើកកម្ពស់ និងអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។

សហគ្រិនខ្មែរ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

សមាគមសហគ្រិនវ័យក្មេងកម្ពុជា

សហព័ន្ធស្វាយចន្ទីកម្ពុជា

សមាគមស្វាយចន្ទីកម្ពុជា

សមាគមអ្នកផលិតចំណីអាហារកម្ពុជា

សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា

សមាគមសហគ្រិនស្ត្រីកម្ពុជា

ក្រុមហ៊ុនបញ្ជីហ្វាញថេក ឯ.ក

ស៊ីអ៊ីអូម៉ាស្ទ័រក្លឹប នៃក្រុមហ៊ុន ឡាយហ្វ៍អេឌ្យូខេសិន ឯ.ក

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍

សភាពាណិជ្ជកម្មកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយនៃក្រសួងហិរញ្ញវត្ថុជប៉ុន

សាជីវកម្មហិរញ្ញវត្ថុជប៉ុន

អង្គការ វ៉ាធើដុតអក់

សាជីវកម្មធានាឥណទាន កម្ពុជា

# ដៃគូទូទាត់សាច់ប្រាក់

“SME Bank” មានគោលដៅពង្រីកវិសាលភាពផ្តល់ហិរញ្ញប្បទាន ជូនដល់ សហគ្រាសធុនតូច និងមធ្យម នៅគ្រប់ខេត្តក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ដោយសារចំនួនសាខា និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យានៅមានកម្រិត ធនាគារបាន និងកំពុង សហការជាមួយស្ថាប័នហិរញ្ញវត្ថុមួយចំនួនក្នុងគោលដៅជួយសម្រួលដល់ ការសងត្រឡប់ប្រាក់កម្ចីមក ធនាគារវិញតាមរយៈបណ្តាញចែកចាយរបស់ស្ថាប័នដៃគូ។

ធនាគារបានចុះកិច្ចសហប្រតិបត្តិការជាមួយ ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់, ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុន ទ្រូម៉ាន់នី (ខេមបូឌា) ដើម្បីផ្តល់លទ្ធភាពឱ្យអតិថិជនរបស់ខ្លួនអាចធ្វើប្រតិបត្តិការសងត្រឡប់ ហិរញ្ញប្បទាន តាមរយៈសេវាទូរស័ព្ទចល័ត។ កិច្ចសហប្រតិបត្តិការនេះផ្តល់នូវបទពិសោធន៍នៃការប្រើប្រាស់សេវាកម្មទូទាត់ប្រាក់ ប្រកបដោយសុវត្ថិភាព និងមានភាពងាយស្រួល។



# លទ្ធផល
# អាជីវកម្ម



គិតត្រឹមចុងឆ្នាំ ២០២៤ សមតុល្យហិរញ្ញប្បទានមានប្រមាណ ២២១ លានដុល្លារអាម៉េរិក ដែលរួមមានគម្រោងហិរញ្ញប្បទានដោយផ្ទាល់ប្រមាណ១២៣លានដុល្លារអាម៉េរិកគម្រោងសហហិរញ្ញប្បទាន ៩២ លានដុល្លារអាម៉េរិក និងគម្រោងហិរញ្ញប្បទានផ្សេងៗ ៦ លានដុល្លារអាម៉េរិក។ ក្នុងឆ្នាំ ២០២៤ “SME Bank” បានបញ្ចេញហិរញ្ញប្បទានដោយផ្ទាល់សរុប ៤៥ លានដុល្លារអាម៉េរិក ដល់ ១៤៣ សហគ្រាស។ ក្នុងនេះផងដែរ ៧១% នៃហិរញ្ញប្បទានដោយផ្ទាល់ត្រូវបានផ្ដល់ទៅឱ្យវិស័យអាទិភាព និង ៥០% នៃហិរញ្ញប្បទាន ក្នុងវិស័យកែច្នៃ និងកម្មន្តសាល។ ធនាគារបានដាក់ឱ្យដំណើរការគម្រោងហិរញ្ញប្បទានដោយផ្ទាល់ ចំនួន ៦ ប្រភេទគឺ

- គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (CSS)
- គម្រោងហិរញ្ញប្បទានសហគ្រិនស្ត្រី (CWES)
- គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS)
- គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច (CMES)
- កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍ នៅខេត្តសៀមរាប (TFSS)
- គម្រោងហិរញ្ញប្បទានប្រតិបត្តិករទឹកស្អាតកម្ពុជា (CWOS)

ឥណទានមិនដំណើរការ (NPL) ក្នុងគម្រោងហិរញ្ញប្បទានដោយផ្ទាល់មាន ១៤% ។

សមតុល្យហិរញ្ញប្បទាន
២២១
លានដុល្លារអាម៉េរិក

គម្រោងហិរញ្ញប្បទានដោយផ្ទាល់
១២៣
លានដុល្លារអាម៉េរិក

គម្រោងសហហិរញ្ញប្បទាន
៩២
លានដុល្លារអាម៉េរិក

# កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍ នៅខេត្តសៀមរាប (TFSS)

ដើម្បីជំរុញវិស័យទេសចរណ៍នៅខេត្តសៀមរាបឱ្យមានសន្ទុះងើបឡើងវិញ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដូចបានកំណត់ត្រង់ចំណុច ៦.២.៤ នៃសេចក្តីជូនដំណឹង ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ ដោយប្រគល់ភារកិច្ចជូន “SME Bank” រៀបចំជាកម្មវិធីផ្តល់កម្ចីដោយផ្ទាល់ ជាមួយនឹងទឹកប្រាក់បឋមចំនួន ៥០ លានដុល្លារអាមេរិក ដល់ប្រតិបត្តិករទេសចរណ៍ខេត្តសៀមរាប។

កម្មវិធីនេះ ផ្តល់ជូននូវអត្រាការប្រាក់សមរម្យ និងលក្ខខណ្ឌអនុគ្រោះផ្សេងៗទៀតដែលអនុញ្ញាតឱ្យប្រតិបត្តិករទេសចរណ៍អាចទទួលបាននូវហិរញ្ញប្បទាន ដើម្បីបើកដំណើរការអាជីវកម្មឡើងវិញ, ធ្វើការកែលម្អ និងធ្វើទំនើបកម្មសេវាទេសចរណ៍ ព្រមទាំងការពង្រីកខ្លួន និងធ្វើពិពិធកម្មសេវាទេសចរណ៍ សំដៅទាក់ទាញ និងទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

**គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២៤ គម្រោង TFSS បានបញ្ចេញហិរញ្ញប្បទានដោយផ្ទាល់ដល់ប្រតិបត្តិករទេសចរណ៍ នៅខេត្តសៀមរាបចំនួន ២៦ ជាមួយទំហំឥណទានសរុបប្រមាណ ១២ លានដុល្លារអាមេរិក។**

គម្រោងថវិកាសរុប
**50** លានដុល្លារអាមេរិក

ឥណទានបានបញ្ចេញ
**12** លានដុល្លារអាមេរិក

អត្រាការប្រាក់ចាប់ពី
**4.00%** ក្នុងមួយឆ្នាំ

អាជីវកម្មដែលទទួលបានឥណទាន
**26**

| | |
|---|---|
| សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន | 76% |
| ភោជនីយដ្ឋាន | 7% |
| សេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរណ៍ | 12% |
| ការផ្គត់ផ្គង់ផលិតផល និង/ឬសេវាកម្មដែលគាំទ្រឧស្សាហកម្មទេសចរណ៍ | 3% |

# គម្រោងហិរញ្ញប្បទានដោយផ្ទាល់


















# ព្រឹត្តិការណ៍ប្រចាំឆ្នាំ



# #OneSME
# ANNUAL GENERAL MEETING



# កិច្ចប្រជុំប្រចាំឆ្នាំ



“SME Bank” បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០២៥ ក្រោមប្រធានបទ «អេសអ៊ឹមអ៊ី តែមួយ (ONE SME)» នារសៀលថ្ងៃសៅរ៍ ទី៨ ខែកុម្ភៈ ឆ្នាំ២០២៥ នៅសណ្ឋាគារណូវ៉ូតែល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល “SME Bank” ព្រមទាំងមានការអញ្ជើញ

ចូលរួម ពីសំណាក់ឯកឧត្តម សមាជិកក្រុមប្រឹក្សាភិបាល, គណៈគ្រប់គ្រង និងបុគ្គលិកធនាគារសរុបប្រមាណ ២១០នាក់។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបូកសរុបវឌ្ឍនភាពការងារប្រចាំឆ្នាំ២០២៤ និងការលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលរួមដែល “SME Bank” សម្រេចបានក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ។







# កម្មវិធីបុគ្គលិកឆ្នើមប្រចាំឆ្នាំ



នារាត្រី ថ្ងៃសៅរ៍ ទី៨ ខែកុម្ភៈ ឆ្នាំ២០២៥ “SME Bank” បានរៀបចំកម្មវិធីជប់លៀងប្រចាំឆ្នាំ ក្រោមប្រធានបទ «៥ឆ្នាំ នៃការអភិវឌ្ឍ និងដំណើរឆ្ពោះទៅមុខ (5 Years Milestone)» នៅភោជនីយដ្ឋានឆ្នេរថ្មី ខេត្តព្រះសីហនុ។

“SME Bank” តែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខុមាលភាពបុគ្គលិក ក៏ដូចជាលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ដោយផ្តល់ជូននូវការទទួលស្គាល់សមិទ្ធផលតាមរយៈការផ្តល់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកឆ្នើមប្រចាំឆ្នាំ ចំពោះកិច្ចខិតខំប្រឹងប្រែបំពេញការងារប្រកបដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈ។










# ព្រឹត្តការណ៍ផ្សេងៗ




ការធ្វើទស្សនកិច្ចសិក្សានៅសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទី អៀង សុខគា, ជ័យ សំបូរ និងសមាគមស្វាយចន្ទីកម្ពុជា

**ថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៤**




ការចូលរួម និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីពី«ការអភិវឌ្ឍន៍អាជីវកម្មក្រោយបរិបទកូវីដ-១៩» ដែលត្រូវបានរៀបចំឡើងដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខេត្តប៉ៃលិន

**ថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី «ជួបជុំអាហារសាមគ្គី និងឱកាសផ្គូផ្គងអាជីវកម្មខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ក្រុងប៉ោយប៉ែត និងរាជធានីភ្នំពេញ ប្រចាំឆ្នាំ២០២៤» ដែលបានរៀបចំឡើង ដោយសភាពាណិជ្ជកម្មខេត្ត និងរដ្ឋបាលខេត្តបាត់ដំបង

**ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីព «ការអភិវឌ្ឍន៍អាជីវកម្មក្រោយបរិបទកូវីដ-១៩» ដែលត្រូវបានរៀបចំឡើង ដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខេត្តកែប

**ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤**




ចូលរួមឧបត្ថម្ភកម្មវិធី «មហាសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ លើកទិសដៅការងារឆ្នាំ២០២៤ និងកម្មវិធីពានរង្វាន់សមាជិកឆ្នើម ២០២៣» របស់សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា

**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤**



ការរៀបចំសិក្ខាសាលាស្តីពី «លទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងការអភិវឌ្ឍទៅរកទីផ្សារពិភពលោក» ដែលសហការរៀបចំឡើងដោយធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងក្រុមហ៊ុន Advance Digital World Trade Co.,ltd. (ADWT)

**ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីពី «ការអភិវឌ្ឍន៍អាជីវកម្មក្រោយបរិបទកូវីដ-១៩» ដែលត្រូវបានរៀបចំឡើងដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខេត្តតាកែវ

**ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤**



ចូលរួមឧបត្ថម្ភព្រឹត្តិការណ៍ទិវាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើកទី២ ក្រោមប្រធានបទ «សហគ្រាសធុនតូច និងមធ្យម ឆ្ពោះទៅវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍» ដែលត្រូវបានរៀបចំឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍

**ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤**




ការទទួលស្វាគមន៍ដំណើរទស្សនកិច្ច របស់សិស្ស និស្សិតពីវិទ្យាស្ថាន CamEd Business School

**ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពី គម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីពី «ការអភិវឌ្ឍន៍អាជីវកម្ម ក្រោយបរិបទកូវីដ-១៩» ដែលត្រូវបានរៀបចំឡើង ដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខេត្តព្រះវិហារ

**ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញ ក្នុងព្រឹត្តិការណ៍ទិវាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើកទី២ ដែលត្រូវបានរៀបចំឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភ ពិធីអបអរសាទរខួប១៥ឆ្នាំ នៃការបង្កើតសមាគមសហគ្រិនវ័យក្មេងកម្ពុជា និង១០ឆ្នាំ នៃការបង្កើតសាខាខេត្តសៀមរាប ដែលត្រូវបានរៀបចំឡើងដោយសមាគមសហគ្រិនវ័យក្មេង កម្ពុជា

**ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះក្នុងកម្មវិធីសិក្ខាសាលាស្តីពី «ការអភិវឌ្ឍអាជីវកម្មក្រោយបរិបទកូវីដ-១៩» ដែលត្រូវបានរៀបចំឡើងដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខេត្តឧត្តរមានជ័យ

**ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះក្នុងកម្មវិធីសិក្ខាសាលាស្តីពី «មូលដ្ឋានគ្រឹះនៃការប្រើប្រាស់សារធាតុបន្ថែម និងការរៀបចំខ្សែសង្វាក់ផលិតកម្ម ស្របតាមស្តង់ដាសុវត្ថិភាពចំណីអាហារ» ដែលបានរៀបចំឡើងដោយ សមាគមអ្នកផលិតចំណីអាហារកម្ពុជា

**ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីពី «ការផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា» ដែលបានរៀបចំឡើងដោយ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តកណ្តាល

**ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីពី «ការអភិវឌ្ឍន៍អាជីវកម្មក្រោយបរិបទកូវីដ-១៩» ដែលត្រូវបានរៀបចំឡើងដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខេត្តកំពង់ធំ

**ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤**




ដំណើរទស្សនកិច្ចសិក្សា នៅវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ (PRI) នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងសាជីវកម្មហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច (JFC-Micro) នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

**ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤**




ដំណើរទស្សនកិច្ចសិក្សានិងការចូលរួមវគ្គបណ្តុះបណ្តាលស្តីពី «ការអភិវឌ្ឍគម្រោងហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យម» នៅទីក្រុងតូក្យូ នៃប្រទេសជប៉ុន រយៈពេល ៥ថ្ងៃ ដែលត្រូវបានសហការរៀបចំឡើងដោយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ (PRI) នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន (JFC-Micro)។

**ថ្ងៃទី២០-២៤ ខែឧសភា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាស្តីពី ការវិនិយោគទេសចរណ៍កម្ពុជាតំបន់ភូមិភាគខាងត្បូង ក្រោមប្រធានបទ «ការវិនិយោគទេសចរណ៍បៃតង (Green Tourism Investment)»

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធី «កិច្ចប្រជុំថ្នាក់តំបន់» ដែលបានរៀបចំឡើងដោយសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា នៅខេត្តបាត់ដំបង

**ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធី «សិក្ខាសាលាផ្សព្វផ្សាយច្បាប់វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងការអនុវត្តវិធីសាស្រ្ត សុវត្ថិភាពអាហារ និងគុណភាពអាហារ» ដែលត្រូវបានរៀបចំឡើងដោយមន្ទីរឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍

**ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធី «កិច្ចប្រជុំថ្នាក់តំបន់» ដែលបានរៀបចំឡើងដោយសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា នៅខេត្តកំពង់ស្ពឺ

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤**




ការចូលរួមសន្និសីទសារព័ត៌មាន ស្តីពីទស្សនកិច្ចពាណិជ្ជកម្ម ខេត្តកោះកុង ដែលត្រូវបានរៀបចំឡើងដោយសភាពាណិជ្ជកម្មកម្ពុជា

**ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤**



ការប្រារព្ធពិធីទូងស្គរ ដើម្បីចូលរួមអបអរសាទរ ការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ

**ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤**




ការទទួលស្វាគមន៍គណៈប្រតិភូធនាគារជាតិសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស សម្រាប់ដំណើរទស្សនកិច្ចសិក្សា

**ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី «ការជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧» ដែលត្រូវបានសហការរៀបចំដោយក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលខេត្តស្ទឹងត្រែង។

**ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤**




ការចូលរួមឧបត្ថម្ភកម្មវិធី និងចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាក្នុង «វគ្គបណ្តុះបណ្តាលស្តីពី ខ្សែចង្វាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ» ដែលបានសហការរៀបចំឡើងដោយសមាគមសហគ្រិនវ័យក្មេងកម្ពុជា, សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុ។

**ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤**



កិច្ចពិភាក្សាស្តីពី «លក្ខខណ្ឌ និងការត្រៀមខ្លួនដើម្បីទទួលបានហិរញ្ញប្បទាន» ដែលត្រូវបានរៀបចំឡើងដោយធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងសភាពាណិជ្ជកម្មកម្ពុជា

**ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី «ជំនួបរវាងសហគ្រិន ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ លើកទី៤» ដែលបានសហការរៀបចំឡើងដោយសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC), សមាគមធនាគារនៅកម្ពុជា (ABC) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)

**ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី និងដាក់បង្ហាញស្តង់ នៅកម្មវិធី ក្រោមប្រធានបទ «តួនាទីនៃគណនេយ្យ និងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា សម្រាប់ចក្ខុវិស័យឆ្នាំ២០៣០»

**ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី «ទិវាសហគ្រិនស្ត្រីកម្ពុជា ឆ្នាំ២០២៤» ដែលត្រូវបានរៀបចំឡើងដោយសមាគមសហគ្រិនស្ត្រីកម្ពុជា

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤**




ការចូលរួមសហការ និងអបអរសាទរ ក្នុងកម្មវិធីសម្ពោធគម្រោង វគ្គបណ្តុះបណ្តាល «លទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម» ដែលត្រូវបានរៀបចំឡើងដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម កម្ពុជា, ក្រុមហ៊ុនមេគង្គអ៊ិនគ្លូស៊ីវ វេនឈ័រ និងគាំទ្រថវិកាដោយមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF)

**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤**



កិច្ចសហប្រតិបត្តិការ ជាមួយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកធនាគារ ទាក់ទង «វិធីសាស្ត្រ នៃការត្រួតពិនិត្យឥណទាន» សម្រាប់សហគ្រាសធុនតូច និងមធ្យម

**ថ្ងៃទី១៩-២០ ខែវិច្ឆិកា ឆ្នាំ២០២៤**



ការចូលរួមឧបត្ថម្ភកម្មវិធី និងដាក់បង្ហាញស្តង់ក្នុងព្រឹត្តិការណ៍ «ទិវាប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព ២០២៤» ដែលត្រូវបានរៀបចំឡើងដោយសហគ្រិនខ្មែរ

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤**



ការចូលរួមព្រឹត្តិការណ៍ជិះកង់ ក្រោមប្រធានបទ «ជិះកង់ដើម្បីផ្សព្វផ្សាយអំពីនិរន្តរភាពនៃវិស័យធនាគារ និងការលើកកម្ពស់ប្រាក់រៀល» ដែលត្រូវបានរៀបចំឡើងដោយ សមាគមធនាគារនៅកម្ពុជា

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤**



ការចូលរួម «ពិធីលៀងសាយភោជនប្រចាំឆ្នាំ ២០២៤» ដែលត្រូវបានរៀបចំឡើងដោយសមាគមធនាគារនៅកម្ពុជា

**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤**



ការចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការ «ថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ»

**ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤**

# ការទទួលខុសត្រូវសង្គម



សកម្មភាពជាក្រុម និងសប្បុរសធម៌ តាមរយៈ កម្មវិធីជិះកង់រួមគ្នា ក្រោមប្រធានបទ «ទង្វើតូច ក្តីស្រឡាញ់ធំ - ជិះកង់ជាមួយ SME Bank» នៅតំបន់ប្រាសាទអង្គរវត្ត

**ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤**



ចូលរួមបរិច្ចាគឈាម ក្នុងកម្មវិធី “បរិច្ចាគឈាម សង្គ្រោះជីវិត” ដែលរៀបចំឡើងដោយ សមាគមធនាគារនៅកម្ពុជា និងមជ្ឈមណ្ឌលជាតិផ្តល់ឈាម

**ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤**



ការចូលរួមបរិច្ចាគថវិកា និងគាំទ្រមូលនិធិគន្ធបុប្ផាកម្ពុជា

**ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤**



ការចូលរួមគាំទ្រដល់យុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» ២០២៤ សម្រាប់កុមារកម្ពុជា ដើម្បីចូលរួមបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤**




ការផ្តល់ជូននូវសម្ភារសិក្សាមួយចំនួន ប្រគល់ជូនសាលាបឋមសិក្សាជាំសង្កែ

**ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤**

# អនុស្សរណៈនៃការយោគយល់




ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និង អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និង សិប្បកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលដៅផ្តោតសំខាន់លើ ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ សហគ្រាសធុនតូច និងមធ្យម

**ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤**




ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និង សភាពាណិជ្ជកម្មកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ លទ្ធភាពទទួលបានហិរញ្ញប្បទាន និងជំរុញវឌ្ឍនភាព ធុរកិច្ច សម្រាប់វិស័យសហគ្រាសធុនតូច និងមធ្យម

**ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤**



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និង អង្គការវ៉ើធើដុតអក់ (Water.org) ក្នុងគោលបំណងជំរុញ លទ្ធភាពនៃការទទួលបានហិរញ្ញប្បទាននៃប្រតិបត្តិករទឹក ស្អាត នៅកម្ពុជា ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ ប្រជាជន និងកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការអភិវឌ្ឍ សេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព។

**ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤**

# អភិបាលកិច្ច សាជីវកម្ម



# រចនាសម្ព័ន្ធធនាគារ





គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ
គណៈកម្មការ ហានិភ័យ និងប្រតិបត្តិតាម
• គណៈកម្មការប្រតិបត្តិ
• គណៈកម្មការឥណទាន
• គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
• គណៈកម្មការវិន័យ
គណៈកម្មការគ្រប់គ្រងហានិភ័យ
នាយកដ្ឋាន ទីផ្សារ
នាយកដ្ឋាន ធនធានមនុស្ស
នាយកដ្ឋាននីតិកម្ម និងលេខាធិការដ្ឋាន
នាយកដ្ឋាន គ្រប់គ្រងហានិភ័យ
នាយកដ្ឋាន ប្រតិបត្តិតាម

# ក្រុមប្រឹក្សាភិបាល





# ក្រុមប្រឹក្សាភិបាល



## ឯកឧត្តមបណ្ឌិត ផាន់ ផល្លា

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាភិបាល

ឯកឧត្តមបណ្ឌិត ផាន់ ផល្លា បានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្នុងឆ្នាំ២០០៤។ ឯកឧត្តមបណ្ឌិត បានចូលរួមយ៉ាងសកម្មក្នុងការងារអភិវឌ្ឍគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMIS), កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP), ការរៀបចំយុទ្ធសាស្រ្តជាតិ និងយុទ្ធសាស្រ្តតាមវិស័យ, យុទ្ធសាស្រ្តកៀរគរចំណូល ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, ការរៀបចំក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣។ល។

បច្ចុប្បន្នឯកឧត្តមបណ្ឌិតមានតួនាទីជាសមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, សមាជិកក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ, អគ្គលេខាធិការនៃអង្គលេខាធិការដ្ឋាន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ “SME Bank”។ ឯកឧត្តមបណ្ឌិតបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចពីប្រទេសអូស្រ្តាលី។



## ឯកឧត្តម សុន សេងហួត

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម សុន សេងហួត ជារដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ និងធ្លាប់មានបទពិសោធន៍ជាច្រើនរួមមាន មុនឆ្នាំ២០១៣ ឯកឧត្តមជាប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី។ ក្នុងឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤ ឯកឧត្តមជាអគ្គនាយករង នៃនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ចាប់ពីឆ្នាំ២០១៤ រហូតមកដល់ពេលបច្ចុប្បន្ន ឯកឧត្តមជារដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ទទួលបន្ទុកអគ្គនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងនាយកដ្ឋានកិច្ចការឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម។

ឯកឧត្តម បានបញ្ចប់ការសិក្សាលើជំនាញគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសវៀតណាម និងជំនាញគ្រប់គ្រងភូមិមួយផលិតផលមួយពីប្រទេសជប៉ុន។ ឯកឧត្តមបានឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសសិង្ហបុរី និងកូរ៉េ។ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យអាស៊ី អឺរ៉ុប។



## ឯកឧត្តម ទេព ភិយ្យោវិទ្ធ

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម ទេព ភិយ្យោវិទ្ធ បច្ចុប្បន្នជាអនុរដ្ឋលេខាធិការនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កន្លងមក ឯកឧត្តមធ្លាប់ជាអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ។ ឯកឧត្តមក៏ធ្លាប់បម្រើ ការងារជាទីប្រឹក្សា នៃនាយកប្រតិបត្តិធនាគារពិភពលោករបស់ World Bank Group ដែលមានទីតាំងនៅទីក្រុង Washington D.C. សហរដ្ឋអាមេរិក។ ឯកឧត្តមបានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងឆ្នាំ១៩៩៩ ក្នុងតំណែងជាមន្ត្រីផ្នែកថវិកា ហើយជាបន្តបន្ទាប់ ឯកឧត្តមក៏បានកាន់តំណែងជាច្រើនដែលរួមមានប្រធានការិយាល័យម៉ាក្រូសេដ្ឋកិច្ច, អនុប្រធាននាយកដ្ឋាន, និងប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

បច្ចុប្បន្នឯកឧត្តមទទួលខុសត្រូវលើការតាមដានការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច, ការត្រួតពិនិត្យគោលនយោបាយ និងវិភាគបញ្ហាអភិវឌ្ឍ។

ឯកឧត្តម បានបញ្ចប់ការសិក្សាផ្នែកគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ពី University of Birmingham នៃចក្រភពអង់គ្លេស និងផ្នែកសេដ្ឋកិច្ច ពី Kharkov State University of Economics នៃប្រទេសអ៊ុយក្រែន។



## លោកស្រី ឈន ដាលិះ

សមាជិកាក្រុមប្រឹក្សាភិបាលឯករាជ្យ

លោកស្រី ឈន ដាលិះ ត្រូវបានតែងតាំងជាសមាជិកាក្រុមប្រឹក្សាភិបាលឯករាជ្យនៃ “SME Bank” នៅឆ្នាំ២០២០។ លោកស្រី មានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងអាជីពជាគណនេយ្យករ និងដឹកនាំ អាជីវកម្មធុនតូច និងមធ្យមក្នុងវិស័យផ្សេងៗរួមមានវិស័យកសិ-ឧស្សាហកម្ម និងវិស័យទឹកស្អាត។

លោកស្រី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម នៅ Asian Institute of Technology ពីប្រទេសថៃ និងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុអន្តរជាតិ នៅ Ceram Sophia Antipolis ពីប្រទេសបារាំង នៅឆ្នាំ២០០២។



## ឯកឧត្តម ចាន់ សុខទី
សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម ចាន់ សុខទី បច្ចុប្បន្នជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក ក្រុមហ៊ុនហ្រ្គីនត្រេដ នៃក្រសួងពាណិជ្ជកម្ម ឋានៈស្មើរដ្ឋលេខាធិការ និងជាសមាជិកក្រុមប្រឹក្សាភិបាល “SME Bank”

ឯកឧត្តម ចាន់ សុខទី ជាសមាជិកគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា (ប.ស.ប.ក) ដែលទទួលខុសត្រូវសម្រាប់គ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងរបស់រាជរដ្ឋាភិបាល។

ឯកឧត្តម ចាន់ សុខទី ធ្លាប់ជាអគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម និងជានាយកគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) ផងដែរ។

ឯកឧត្តម បានចូលបម្រើការងារនៅក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ១៩៩៧ ក្នុងតំណែងជាមន្រ្តីការិយាល័យមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋានកាំកុងត្រូល ហើយបន្តបន្ទាប់ បានកាន់តំណែងជាច្រើនរួមមាន៖ ជាអនុប្រធានសាខាផែស្វូតចុងទី, ជាអនុប្រធាននាយកដ្ឋាន និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកស្តីទីនៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ឯកឧត្តម ចាន់ សុខទី បានបញ្ចប់ការសិក្សាផ្នែកវិស្វករគីមីចំណីអាហារនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងអនុបណ្ឌិតផ្នែកកសិកម្មនៅសាកលវិទ្យាល័យតូក្យូប្រទេសជប៉ុន។



## ឯកឧត្តមបណ្ឌិត គង់ ម៉ារី
មន្ត្រីត្រួតពិនិត្យរដ្ឋ

ឯកឧត្តមបណ្ឌិត គង់ ម៉ារី មានមុខតំណែងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” ជាប្រធានមូលនិធិអភិវឌ្ឍន៍សហគ្រិន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ នៅក្នុងក្របខណ្ឌការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមទទួលភារកិច្ចក្នុងការជួយជំរុញការងារកែទម្រង់តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, ការកសាងធុរកិច្ចថ្មី និងសហគ្រិនភាព, ការជំរុញសហគ្រាសធុនតូច និងមធ្យមឆ្ពោះទៅរកការចាប់យកឌីជីថល និងការលើកកម្ពស់នវានុវត្តន៍ក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ឯកឧត្តមបណ្ឌិត បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតពីសាកលវិទ្យាល័យវ៉ាសេដាប្រទេសជប៉ុនផ្នែកបច្ចេកវិទ្យាព័ត៌មាន។

# គណៈគ្រប់គ្រងជាន់ខ្ពស់



# គណៈគ្រប់គ្រងជាន់ខ្ពស់



## លោក ជា សុភ័ក្ត

អគ្គនាយក

លោក ជា សុភ័ក្ត បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកអភិវឌ្ឍន៍ និងសេដ្ឋកិច្ចអន្តរជាតិ ពីសាលកវិទ្យាល័យជាតិអូស្ត្រាលី និងបានចូលបម្រើការងារ ជាសេដ្ឋកិច្ចវិទូវ័យក្មេង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០១៥។ អំឡុងពេល បំពេញការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោកត្រូវបានចាត់បញ្ជូនឱ្យទៅបំពេញការងារជាទីប្រឹក្សាក្រុមប្រឹក្សាភិបាល តំណាងព្រះរាជាណាចក្រកម្ពុជា ប្រចាំធនាគារអភិវឌ្ឍន៍អាស៊ី មានទីស្នាក់ការក្នុងទីក្រុងម៉ានីល នៃប្រទេសហ្វីលីពីន រយៈពេល ២ ឆ្នាំ។

លោក ត្រូវបានចាត់តាំងឱ្យមកបម្រើការងារនៅ “SME Bank” ជានាយកប្រតិបត្តិ ហិរញ្ញវត្ថុ ក្នុងខែមករា ឆ្នាំ២០២៤។ បច្ចុប្បន្ន លោកទទួលបានការតែងតាំងជា អគ្គនាយក “SME Bank” ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល នាខែមេសា ឆ្នាំ២០២៥។



## លោក អឿ វិបុល

នាយកប្រតិបត្តិឥណទាន

លោក អឿ វិបុល មានបទពិសោធន៍ការងារជាង ១៧ឆ្នាំក្នុងវិស័យធនាគារ។ លោកចាប់ផ្តើមអាជីពនៅធនាគារក្នុងស្រុកឈានមុខគេមួយចាប់តាំងពីឆ្នាំ២០០៤ ជាមួយនឹងតួនាទីជាច្រើន ក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០១០ លោកបានផ្លាស់ទៅបម្រើការងារក្នុងធនាគារមួយនៃធនាគារដ៏ធំក្នុងតំបន់ ជាអ្នកចូលរួមក្នុងការបង្កើតធនាគារដំបូង ដែលអាចផ្តល់បន្ថែមនូវបទពិសោធន៍ និងវិជ្ជាជីវៈផ្នែកគណនេយ្យ, ហិរញ្ញវត្ថុ, និងការគ្រប់គ្រងហានិភ័យ ព្រមទាំងតួនាទីចុងក្រោយជានាយកផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យ ជាមួយទំនួលខុសត្រូវចម្បង គឺការអភិវឌ្ឍ និងការអនុវត្តក្របខ័ណ្ឌ និងគោលនយោបាយគ្រប់គ្រងហានិភ័យឱ្យស្របនឹងប្រតិបត្តិការ និងបទប្បញ្ញត្តិនានា។

នៅក្នុងខែសីហា ឆ្នាំ២០២០ លោកបានចូលបម្រើការងារជាមួយ “SME Bank” ក្នុងតួនាទីជានាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ ដើម្បីត្រួតពិនិត្យមុខងារគ្រប់គ្រងហានិភ័យរួមមានហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ។

នៅក្នុងឆ្នាំ២០០៤ លោកបានបញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។



## លោក ដែន ដារុទ្ធ

នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន

លោក ដែន ដារុទ្ធ បានចាប់ផ្តើមអាជីពរបស់គាត់នៅឆ្នាំ២០០៥ជាមួយនឹងធនាគារក្នុងស្រុកមួយក្នុងផ្នែកព័ត៌មានវិទ្យា។ លោកបានចូលបម្រើការងារនៅ “SME Bank” នៅខែកក្កដា ឆ្នាំ២០២១ ជានាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលមានទំនួលខុសត្រូវចម្បងដូចជាការអនុវត្តគោលការណ៍ យុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានវិទ្យា ដឹកនាំការកែលម្អ ពន្លឿនប្រព័ន្ធ ប្រតិបត្តិការផ្សេងៗ និងគ្រប់គ្រង និងពង្រឹងការពារហានិភ័យព័ត៌មានវិទ្យា។

នៅឆ្នាំ២០១០ លោកជាបុគ្គលិកក្នុងចំណោមអ្នកចូលរួមដំបូងក្នុងការបង្កើតស្ថាប័នធនាគារថ្មី នៃធនាគារធំក្នុងតំបន់មួយមានតួនាទីជានាយកនាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩ លោកបានដឹកនាំអនុវត្តគម្រោងធនាគារក្នុងស្រុកថ្មីមួយលើការដំឡើងប្រព័ន្ធហេដ្ឋា រចនាសម្ព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធធនាគារឌីជីថលថ្មី។ ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១ លោកជានាយកប្រតិបត្តិបច្ចេកទេសព័ត៌មានវិទ្យា និងឌីជីថល នៃធនាគារស្ថាបនា។

លោកបានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ២០០៤ បរិញ្ញាបត្រផ្នែកទំនាក់ទំនងសាធារណៈ ពីវិទ្យាស្ថានភាសាបរទេសនៅឆ្នាំ២០០៩ និងទទួលបានវិញ្ញាបនប័ត្រផ្នែកគ្រប់គ្រង និងដឹកនាំពីមហាវិទ្យាល័យបច្ចេកទេសណានយ៉ាងប្រទេសសឹង្ហបុរី នៅឆ្នាំ២០១៣។



## លោក ហួត សុខា

នាយកប្រតិបត្តិអាជីវកម្ម

លោក ហួត សុខា ចូលរួមជាមួយ “SME Bank” ក្នុងតួនាទីជា នាយកប្រតិបត្តិអាជីវកម្ម ដើម្បីគ្រប់គ្រងផែនការអាជីវកម្ម, ប្រតិបត្តិការ ការលក់, សាខា និងយុទ្ធសាស្ត្រចែកចាយ ចាប់តាំងពីដើមខែមីនា ឆ្នាំ២០២៥។ លោកមានបទពិសោធន៍ជាង ២៥ឆ្នាំ ក្នុងតួនាទីគ្រប់គ្រង និងដឹកនាំក្នុងក្រុមហ៊ុនពាណិជ្ជកម្មអន្តរជាតិ, ស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារ និងឧស្សាហកម្មសម្លៀកបំពាក់។

លោកបានបញ្ចប់ ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រង និងទីផ្សារនៅសាកលវិទ្យាល័យ MVU ក្នុងឆ្នាំ១៩៩៧ និងបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យ Charles Stuart ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០០៤។ លោកក៏បានបញ្ចប់កម្មវិធីអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុនៅសាកលវិទ្យាល័យ NAROPA រដ្ឋកូឡូរ៉ាដូ សហរដ្ឋអាមេរិកផងដែរ។



# អភិបាលកិច្ចសាជីវកម្ម

ធនាគារមានអភិបាលកិច្ចដ៏រឹងមាំ ក្រោមអាណាព្យាបាលបច្ចេកទេសនិងហិរញ្ញវត្ថុពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការត្រួតពិនិត្យបន្ថែមពីធនាគារជាតិ នៃកម្ពុជា។ ធនាគារត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានក្រុមប្រឹក្សាភិបាល និងសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

ធនាគារ បានអនុវត្តការងារផ្អែកលើគោលការណ៍, បទប្បញ្ញត្តិ, នីតិវិធី, ការផ្ទៀងផ្ទាត់, និងយន្តការវាយតម្លៃដែលបានរៀបចំឡើងដោយគណៈគ្រប់គ្រង និងផ្នែកពាក់ព័ន្ធផ្សេងៗក្នុងធនាគារ និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួនប្រាំពីរ (០៧) រូប រួមមាន អភិបាលប្រតិបត្តិចំនួន ២ រូប និងអភិបាលមិនប្រតិបត្តិចំនួន៥រូប។ ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានទទួលខុសត្រូវកំណត់គោលដៅ និងត្រួតពិនិត្យការគ្រប់គ្រង និងកិច្ចការទូទៅរបស់ធនាគារ ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល និងបទប្បញ្ញត្តិរបស់អាជ្ញាធរពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងទទួលខុសត្រូវ ចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ម្ចាស់ភាគហ៊ុនតែមួយគត់) លើការប្រព្រឹត្តទៅនៃអាជីវកម្មរបស់ធនាគារ។

ក្នុងឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានជួបប្រជុំចំនួន ៦ លើក ដើម្បីពិនិត្យ និងអនុម័តលើកិច្ចការសំខាន់ៗ ដូចជា វឌ្ឍនភាពនៃប្រតិបត្តិការធនាគារជាប្រចាំ, លក្ខខណ្ឌមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល, ផលិតផលឥណទានឡើងវិញ, ផែនការអាជីវកម្មសម្រាប់រយៈពេល ៣ ឆ្នាំ២០២៥-២០២៧, ផែនការលទ្ធកម្មសម្រាប់ឆ្នាំ២០២៥ និងកែសម្រួល និងធ្វើបច្ចុប្បន្នភាពគោលនយោបាយសំខាន់ៗមួយចំនួន។



# គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម

គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងមានអភិបាលមិនប្រតិបត្តិ ចំនួន បួន (០៤) រូប។ គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម ត្រូវទទួលខុសត្រូវជាអប្បបរមាលើការតាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម ត្រួតពិនិត្យលើហានិភ័យឥណទាន, ហានិភ័យសន្ទនីយភាព, ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការរួមមានការពិនិត្យឡើងវិញនូវហានិភ័យយុទ្ធសាស្ត្រគោលនយោបាយ គោលការណ៍វិធីសាស្ត្រ វាយតម្លៃ និងរបាយការណ៍គ្រប់គ្រងហានិភ័យ។ គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម មានតួនាទីរាយការណ៍ទៅ ក្រុមប្រឹក្សាភិបាលស្តីពីបញ្ហាគ្រប់គ្រងហានិភ័យទាំងអស់របស់ធនាគារ។

កិច្ចប្រជុំគណៈកម្មការហានិភ័យ និងប្រតិបត្តិតាម នៅឆ្នាំ២០២៤ បានរៀបចំឡើងចំនួន ១២ ដង ដែលមានការអញ្ជើញ ចូលរួម ពីសមាជិក-សមាជិកា ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | ប្រធាន |
| ២ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៣ | ឯកឧត្តម ចាន់ សុខទី | សមាជិក |
| ៤ | លោកស្រី ឈន ដាលិះ | សមាជិកា |

តួនាទី និងភារកិច្ចរបស់គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម មានដូចខាងក្រោម៖

## | ការងារគ្រប់គ្រងហានិភ័យ

- ដើម្បីពិនិត្យរៀបចំ និងណែនាំគោលនយោបាយ ទាក់ទងនឹងបញ្ហាយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ
- វិសេចលើវិន (Risk Tolerance) និងគោលនយោបាយផ្សេងៗទៀត សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត។
- ពិនិត្យ និងផ្តល់អនុសាសន៍លើសំណើកែប្រែផលិតផល និងគោលនយោបាយផ្សេងៗ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- ពិនិត្យ និងផ្តល់អនុសាសន៍ លើសំណើសុំឥណទានមុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- ពិនិត្យ និងអនុម័តលើនីតិវិធីផ្សេងៗដែលជំនួយដល់ការអនុវត្តគោលនយោបាយ។

- អនុម័តលើគោលនយោបាយដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយការផ្លាស់ប្តូរ ឬកែប្រែតិចតួច។
- ពិនិត្យ និងពិចារណាលើភាពគ្រប់គ្រាន់នៃគោលនយោបាយ និងក្របខ័ណ្ឌការគ្រប់គ្រងហានិភ័យ ការកំណត់ការវាស់វែង ការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យ ដែលប្រតិបត្តិការទាំងនេះអាចអនុវត្តដោយមានប្រសិទ្ធភាព។
- ដើម្បីធានាឱ្យបានថាហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធ ដែលមានសម្រាប់ការគ្រប់គ្រងហានិភ័យ ត្រូវធានាថាបុគ្គលិកដែលទទួលខុសត្រូវក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យអនុវត្តភារកិច្ចទាំងនោះ ដោយឯករាជ្យលើសកម្មភាពហានិភ័យ ដែលអាចទទួលយកបានរបស់ “SME Bank”។
- ពិនិត្យមើលឡើងវិញនូវរបាយការណ៍ជាប្រចាំ របស់អ្នកគ្រប់គ្រងទៅលើហានិភ័យប្រឈម សមាសធាតុហានិភ័យប្រឈមប្រព័ន្ធវាយតម្លៃហានិភ័យរីសអាប់ភៃថាយ (Risk Appetite) ការធ្វើស្រ្តេសតេស្ត និងសកម្មភាពគ្រប់គ្រងហានិភ័យ។
- ធានាបានការទទួលស្គាល់តណទានមិនដំណើរការ អនុលោមទៅតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័ត និងបទប្បញ្ញត្តិនានាដែលមាន។
- ពិនិត្យ និងអនុម័តសកម្មភាពហានិភ័យដែលអាចទទួលយកដូចដែលបានផ្តល់សិទ្ធិ។
- ការពិចារណា និងផ្តល់ការយល់ព្រមជាមុន លើការជ្រើសរើស ការតែងតាំង និងការបញ្ឈប់នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ។
- ដើម្បីបង្កើត និងត្រួតពិនិត្យអនុគណៈកម្មការណាមួយ ដែលអាចមានប្រយោជន៍ទៅដល់មុខងារ និងការទទួលខុសត្រូវរបស់គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម។
- បំពេញនូវភារកិច្ចទាក់ទងនឹងការគ្រប់គ្រងលើហានិភ័យផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល។

## | ការងារប្រតិបត្តិតាម

- ពិភាក្សាលើបញ្ហាប្រតិបត្តិតាម និងបញ្ហាហានិភ័យ ពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងធានាថាបញ្ហាទាំងនោះ ត្រូវបានធ្វើការដោះស្រាយប្រកបដោយប្រសិទ្ធភាព។
- ពិនិត្យ និងគាំទ្រការប្រតិបត្តិតាម និងក្របខ័ណ្ឌ/គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធប្រល័យលោក ការកែប្រែសំខាន់ៗ លើការប្រតិបត្តិតាម និងក្របខ័ណ្ឌគោលនយោបាយហានិភ័យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- វាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងជារួមលើហានិភ័យប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធប្រល័យលោក របស់ “SME Bank”។ ផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងពង្រឹងមុខងារប្រតិបត្តិតាម ធនធាន និងហេដ្ឋារចនាសម្ព័ន្ធ។
- ទទួល និងពិនិត្យឡើងវិញយ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ នូវរបាយការណ៍ស្តីពីការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលផ្តល់ជូនដោយមន្ត្រីរាយការណ៍ អំពីការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធប្រល័យលោក និងសកម្មភាពជាក់លាក់ណាមួយ ដែលបានអនុវត្តដោយថ្នាក់ដឹកនាំទាក់ទងនឹងរបាយការណ៍។

- ពិនិត្យឡើងវិញដើម្បីជួយក្នុងការដឹកនាំ និងត្រួតពិនិត្យការអភិវឌ្ឍបច្ចេកទេស នៃការប្រតិបត្តិតាម FATCA និងធ្វើរបាយការណ៍ទៅនិយ័តករដែលពាក់ព័ន្ធ។
- រាយការណ៍ទៅក្រុមប្រឹក្សាភិបាលលើការពិចារណានូវបញ្ហាខាងលើ ដោយកំណត់បានផ្នែកដែលត្រូវការសកម្មភាព ឬការកែលម្អ និងផ្តល់អនុសាសន៍តាមភាពសមស្រប។
- ពិនិត្យឡើងវិញ នូវរបាយការណ៍ពីមន្ត្រីប្រតិបត្តិតាម ស្តីពីការរៀបចំនាទា ដែលរៀបចំដោយអ្នកគ្រប់គ្រង ដើម្បីធានាឱ្យបានការប្រកាន់ខ្ជាប់នូវគោលនយោបាយ និងនីតិវិធីប្រតិបត្តិតាមផ្ទៃក្នុង និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាក់លាក់ តាមការស្នើសុំរបស់គណៈកម្មការ ឬតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ។
- ការពិចារណា និងផ្តល់ការយល់ព្រមជាមុនលើការជ្រើសរើស តែងតាំង និងដកមន្ត្រីប្រតិបត្តិតាម។
- ពិចារណា និងពិនិត្យលើបញ្ហាផ្សេងៗ ដែលក្រុមប្រឹក្សាភិបាលធ្វើការណែនាំឱ្យកែតម្រូវ និងយកចិត្តទុកដាក់នូវចំណុចដែលត្រូវ បានតម្រូវ ឬ/និងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលតាមការសមស្រប។

## | ការងារសំខាន់ៗដែលបានត្រួតពិនិត្យ និងអនុម័តដោយគណៈកម្មការហានិភ័យ និងប្រតិបត្តិតាម

ក្នុងអំឡុងឆ្នាំ ២០២៤ គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម បានត្រួតពិនិត្យ និងអនុម័តលើការងារសំខាន់ៗមានដូចខាងក្រោម ៖

- របាយការណ៍គ្រប់គ្រងហានិភ័យ
- របាយការណ៍ស្តីពីហានិភ័យប្រតិបត្តិតាមបទប្បញ្ញត្តិ និងហានិភ័យប្រតិបត្តិតាម
- ឯកសារវិសអាប់ភែថាយ (Risk Appetite)
- លក្ខខណ្ឌមុខងារ និងភារកិច្ចរបស់គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម (BRCC’s TOR)
- គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធប្រល័យលោក
- គោលនយោបាយប្រតិបត្តិតាម
- គោលនយោបាយគ្រប់គ្រងហានិភ័យ
- គោលនយោបាយគ្រប់គ្រងហានិភ័យប្រតិបត្តិការ
- ការលើកលែងបណ្តោះអាសន្ននៃហានិភ័យសុវត្ថិភាពបច្ចេកវិទ្យា
- ក្របខណ្ឌអនុម័តគោលនយោបាយ និងផលិតផលថ្មី
- គោលនយោបាយផែនការបន្តនិរន្តភាពអាជីវកម្ម
- គោលនយោបាយគ្រប់គ្រងហានិភ័យសទ្ធនីយភាព
- គោលនយោបាយផែនការថវិកាយថាភាព
- ផែនការសកម្មភាពកំឡុងពេលមានវិបត្តិសទ្ធនីយភាព
- ការលើកលែងកម្រៃឥណទាន (ទុន) បង្វិល
- សំណើឥណទាន
- នីតិវិធីឥណទានដែលបានកែប្រែ និងសំណើទាក់ទងឥណទានផ្សេងទៀត

- សិទ្ធិអនុម័តឥណទានដែលបានកែប្រែ
- គោលនយោបាយបច្ចេកវិទ្យា
- ផែនការអាជីវកម្មសម្រាប់ឆ្នាំ ២០២៥ -២០២៧
- គម្រោងកម្ចីសម្រាប់កាណូតដឹកភ្ញៀវទេសចរ
- ការប្រើប្រាស់ Cloud Computing Services
- សិទ្ធិអនុម័តហិរញ្ញវត្ថុ
- ទម្រង់របាយការណ៍ប្រតិបត្តិតាម
- នីតិវិធីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធប្រល័យលោក
- អត្រាខាតបង់ឥណទានដើម្បីគណនាការខាតបង់ឥណទានដែលបានរំពឹងទុក
- លទ្ធផលនៃការធ្វើស្ត្រេសតេស្ត និងការវិភាគក្នុងឆ្នាំ២០២៤

## | ផ្នែកគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យដើរតួនាទីចម្បងក្នុងវិស័យធនាគារ និងកាន់តែសំខាន់ក្នុងស្ថានភាពសេដ្ឋកិច្ចមិនច្បាស់លាស់។ វប្បធម៌ គ្រប់គ្រងហានិភ័យត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកនីមួយៗនៃអាជីវកម្ម ដើម្បីធានានូវភាពគ្រប់គ្រាន់នៃប្រព័ន្ធគ្រប់គ្រងហានិភ័យក្នុងកម្រិតមួយដែលអាចទទួលយកបានសម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាព។ ការគ្រប់គ្រងហានិភ័យមានមុខងារឯករាជ្យនិងធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកពាក់ព័ន្ធដើម្បីធានាបាននូវប្រព័ន្ធនិងវប្បធម៌គ្រប់គ្រងហានិភ័យល្អ ប្រកបដោយភាពរឹងមាំ។

ជាការសន្និដ្ឋានរួម ការគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវចំពោះមុខងារគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ក៏ដូចជាការត្រួតពិនិត្យហានិភ័យប្រឈមរបស់ធនាគារនិងធ្វើការរាយការណ៍ជាប្រចាំទៅគណៈកម្មការហានិភ័យនិងប្រតិបត្តិតាម។

## ធនាគារបានផ្តោតសំខាន់ទៅលើហានិភ័យចម្បងៗមួយចំនួនដូចខាងក្រោម៖

### | ហានិភ័យឥណទាន

ជាការខាតបង់ដែលកើតឡើងដោយភាគីអ្នកខ្ចីឬដៃគូសហការខកខានមិនបានអនុវត្តកាតព្វកិច្ចសងតាមកិច្ចសន្យារបស់ខ្លួនជាមួយធនាគារ។ ដំណាក់កាលនៃការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានផ្តោតសំខាន់លើការវិភាគអនុម័ត និងតាមដានឥណទានប្រកបដោយភាពឯករាជ្យ និងវិជ្ជាជីវៈ ដើម្បីធ្វើឱ្យប្រាកដថាលក្ខខណ្ឌដែលបានអនុម័តត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ផ្នែកគ្រប់គ្រងឥណទានអនុវត្តតួនាទីនៃការដាស់តឿន និងតាមដាន ដើម្បីធានាថាលក្ខខណ្ឌដែលបានអនុម័ត ត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ផ្នែកគ្រប់គ្រងឥណទានក៏មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យឥណទានទាំងអស់របស់ធនាគារ និងកម្រិតកំណត់ដែលទាក់ទងនឹងឥណទាន។ ផ្នែកត្រួតពិនិត្យគុណភាពឥណទាន និងផ្នែកត្រួតពិនិត្យ និងស្តារឥណទាន មានតួនាទីពង្រឹងគុណភាពទ្រព្យសកម្ម និងនិរន្តរភាពរយៈពេលវែងរបស់ធនាគារផងដែរ។ ការអភិវឌ្ឍជំនាញនៃការគ្រប់គ្រងហានិភ័យឥណទានជូនដល់គ្រប់បុគ្គលិកពាក់ព័ន្ធ ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយហានិភ័យឥណទាន។

## | ហានិភ័យសន្ទនីយភាព

ហានិភ័យដែលធនាគារមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ផ្តល់ផ្គង់ដល់ការរីកចម្រើន ឬបំពេញកាតព្វកិច្ចនៃកិច្ចសន្យារបស់ខ្លួនដោយមិនមានការខាតបង់ដែលមិនអាចទទួលយកបាន។

ធនាគារ ត្រូវរក្សាកម្រិតសន្ទនីយភាពឱ្យបានគ្រប់គ្រាន់ គ្រប់ពេលវេលាដូចជាស្ថានភាពរំហូរសាច់ប្រាក់ និង/ឬ ទ្រព្យសកម្ម ដែលងាយស្រួលក្នុងការដោះដូរ ដើម្បីអាចបំពេញបានទៅតាមកាតព្វកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិក្រោមលក្ខខណ្ឌអាជីវកម្ម ធម្មតា និងស្ថានភាពស្ត្រេស។

ការទទួលយកហានិភ័យសន្ទនីយភាពរបស់ធនាគារត្រូវបានគ្រប់គ្រងដោយ Liquidity Risk Appetite កំណត់កម្រិត ហានិភ័យសន្ទនីយភាព ដែលធនាគារនឹងទទួលយកតាមយុទ្ធសាស្ត្រ និងគោលដៅអាជីវកម្មរបស់ខ្លួន។ រីសអាប់ភៃថាយ (Risk Appetite) គិតគូរពីកំណើនផលចំណូល និងគោលបំណងអាជីវកម្មរបស់ធនាគារ ក៏ដូចជាសមត្ថភាពគ្រប់គ្រងហានិភ័យ។

តួនាទីគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវតាមដានដោយឯករាជ្យនូវទម្រង់ហានិភ័យសន្ទនីយភាពរបស់ធនាគារ និងផ្តល់របាយការណ៍ជាប្រចាំដល់គណៈកម្មការគ្រប់គ្រងហានិភ័យ (កម្រិតប្រតិបត្តិ) ក៏ដូចជាគណៈកម្មការហានិភ័យ និងប្រតិបត្តិតាម ដើម្បីឱ្យធនាគារចាត់ចែងស្ថានភាពសន្ទនីយភាព ហើយឆ្លើយតបនឹងតម្រូវការប្រតិបត្តិការប្រចាំថ្ងៃ និងតម្រូវការបទប្បញ្ញត្តិ។

## | ហានិភ័យទីផ្សារ

ត្រូវបានកំណត់ថាជាការប្រែប្រួល នៅក្នុងតម្លៃទីផ្សារហិរញ្ញវត្ថុ ដោយសារតែការផ្លាស់ប្តូរ អត្រាហានិភ័យទីផ្សារ ដូចជា អត្រាការប្រាក់, ប្តូរប្រាក់ និងការប៉ះពាល់លើប្រាក់ចំណេញតណទាន, តម្លៃភាគហ៊ុន, តម្លៃទំនិញ និងបម្រែបម្រួលពីកត្តាផ្សេងៗដែលពាក់ព័ន្ធ។

## | ហានិភ័យប្រតិបត្តិការ

សំដៅទៅលើហានិភ័យនៃការបាត់បង់ដែលបណ្តាលមកពីភាព មិនគ្រប់គ្រាន់ ឬបរាជ័យនៃដំណើរការផ្ទៃក្នុងមនុស្ស និងប្រព័ន្ធ ឬព្រឹត្តិការណ៍ខាងក្រៅ។ ហានិភ័យប្រតិបត្តិការ បានរួមបញ្ចូល ទាំងហានិភ័យផ្នែកច្បាប់ ប៉ុន្តែមិនមានហានិភ័យយុទ្ធសាស្ត្រ និង ហានិភ័យកេរ្តិ៍ឈ្មោះទេ។ តម្រូវការសំខាន់មួយនៃរចនាសម្ព័ន្ធ គ្រប់គ្រងហានិភ័យរឹងមាំគឺត្រូវមានឧបករណ៍គ្រប់គ្រងហានិភ័យ ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពដើម្បីកំណត់វាស់វែង តាមដាន ត្រួតពិនិត្យ និងរាយការណ៍អំពីហានិភ័យប្រតិបត្តិការរបស់ធនាគារ។

# គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្ម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល និងមានអភិបាលមិនប្រតិបត្តិចំនួនបួន (០៤) រូប ដើម្បីផ្តល់ការត្រួតពិនិត្យឯករាជ្យទៅលើសវនកម្មផ្ទៃក្នុង, របាយការណ៍ហិរញ្ញវត្ថុ, ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង, និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ដើម្បីធានាដល់ការត្រួតពិនិត្យ និងសមតុល្យ ព្រមទាំងសមភាព និងអនុលោមតាមតម្រូវការបទប្បញ្ញត្តិនៅក្នុងធនាគារ។ ការប្រជុំរបស់គណៈកម្មការសវនកម្ម នៅឆ្នាំ២០២៤ សរុបចំនួនប្រាំបួន (០៩) ដង ហើយមានការចូលរួមពីសមាជិក-សមាជិកា ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | លោកស្រី ឈន ដាលិះ | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៤ | ឯកឧត្តម ចាន់ សុខទី | សមាជិក |

គណៈកម្មការសវនកម្ម អនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធានាថា ព័ត៌មានដែលបានផ្តល់ជូនដល់សាធារណជន និងធនាគារជាតិ នៃ កម្ពុជា មានភាពច្បាស់លាស់ ត្រឹមត្រូវ និងអាចទុកចិត្តបាន
- ធានាថា សវនករផ្ទៃក្នុងធ្វើសវនកម្មជាទៀងទាត់នូវវិធីសាស្ត្រគណនេយ្យកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឆ្លើយតបនឹងការរំពឹងទុកនៃបទប្បញ្ញត្តិ និងក្រុមប្រឹក្សាភិបាល
- វាយតម្លៃ ត្រួតពិនិត្យ និងអនុម័ត ទៅលើគោលនយោបាយសវនកម្មផ្ទៃក្នុង នីតិវិធី និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ជាពិសេសប្រព័ន្ធសម្រាប់រាស់តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យមានភាពស៊ីសង្វាក់គ្នា និងផ្តល់អនុសាសន៍នូវចំណុចខ្វះខាត
- ជួយដល់ក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការអនុវត្តស្តីពីគោលនយោបាយគណនេយ្យ និងការរៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង
- ធានាឱ្យបាននូវសកម្មភាពកែតម្រូវ ដែលបានព្រមព្រៀងរវាងសវនករផ្ទៃក្នុង និងគណៈគ្រប់គ្រង ដើម្បីអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់

## | សមិទ្ធផលដែលគណៈកម្មការសវនកម្មសម្រេចបានក្នុងឆ្នាំ២០២៤៖

- ពិនិត្យ និងផ្តល់ជាអនុសាសន៍លើការរកឃើញរបស់សវនកម្មផ្ទៃក្នុង

- ពិភាក្សាអំពីសូចនាករវាយតម្លៃលទ្ធផលការងារសម្រាប់ក្រុមសវនកម្មផ្ទៃក្នុង, កញ្ចប់ថវិកា, និងចំនួនបុគ្គលិក
- ត្រួតពិនិត្យការអនុវត្តតាមអនុសាសន៍ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគណៈកម្មការសវនកម្ម
- ពិនិត្យ និងអនុម័តលើការធ្វើបច្ចុប្បន្នកម្មលើវិធីសាស្ត្រសវនកម្មផ្ទៃក្នុង
- ពិនិត្យ និងឯកភាពលើសំណើជ្រើសរើសសវនករឯករាជ្យ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ដឹកនាំកិច្ចប្រជុំ រវាងគណៈគ្រប់គ្រងជាមួយសវនករឯករាជ្យ លើការរកឃើញរបស់សវនករឯករាជ្យ
- ត្រួតពិនិត្យលើរបាយការណ៍សវនកម្មប្រចាំឆ្នាំ ២០២៤ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត ព្រមទាំងរាយការណ៍ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងដែលបានអនុម័ត ២០២៤ រាយការណ៍ជូនទៅធនាគារជាតិ នៃ កម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ពិនិត្យលើវគ្គបណ្តុះបណ្តាលសម្រាប់សវនករផ្ទៃក្នុង ដើម្បីពង្រឹងនូវសមត្ថភាព
- ពិនិត្យ និងអនុម័តផែនការការងារនៃសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២៤
- វាយតម្លៃការអនុវត្តប្រចាំឆ្នាំរបស់នាយិកាគ្រប់គ្រងនាយដ្ឋានសវនកម្មផ្ទៃក្នុង។

## | សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងមានតួនាទីក្នុងការវាយតម្លៃ ត្រួតពិនិត្យ តាមដាន ការអនុវត្ត ទៅលើដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចរបស់ធនាគារជាប្រចាំ ដើម្បីឱ្យប្រាកដថាទទួលបានលទ្ធផលសមស្របទៅតាមទស្សនៈវិស័យ និងកម្មវត្ថុដែលធនាគារកំណត់ប្រកបដោយប្រសិទ្ធភាព។ ដើម្បីធានាបាននូវតម្លាភាព និងឯករាជ្យភាពនៃការងារសវនកម្ម សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនទៅគណៈកម្មការសវនកម្ម និងរាយការណ៍ដោយប្រយោលជូនទៅអគ្គនាយក លើការងាររដ្ឋបាលមួយចំនួន។

### តួនាទីសវនករផ្ទៃក្នុង៖

- គ្រប់គ្រងការងារសវនកម្ម តួនាទី សម្របសម្រួលពិនិត្យឡើងវិញ និងរាយការណ៍អំពីការងារ របស់សវនករផ្ទៃក្នុង និងផ្តល់ជំនាញក្នុងស្តង់ដាសវនកម្ម និងលក្ខណៈវិនិច្ឆ័យការអនុវត្ត និងតម្រូវការរបស់សវនកម្មផ្ទៃក្នុង។
- រៀបចំផែនការចាត់ចែង និងត្រួតពិនិត្យសកម្មភាព និងការងារប្រចាំថ្ងៃរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរក្សាទំនាក់ទំនងអតិថិជន និងបុគ្គលិកប្រកបដោយប្រសិទ្ធភាព ព្រមទាំងប្រសិទ្ធផល។
- ធានាឱ្យបានថារាល់គោលនយោបាយ និងនីតិវិធីផ្ទៃក្នុង ត្រូវបានអនុវត្តយ៉ាងពេញលេញដោយគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារ។

- ណែនាំការគ្រប់គ្រងទៅលើផលប៉ះពាល់នៃហានិភ័យដែលទាក់ទងនឹងផលិតផល សេវាកម្ម ឬសកម្មភាពថ្មីៗ និងផែនការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យទាំងនោះ។
- រៀបចំ និងធ្វើបច្ចុប្បន្នភាពផែនការសវនកម្មផ្អែកលើហានិភ័យផ្ទៃក្នុងសម្រាប់វាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងរាយការណ៍របាយការណ៍សវនកម្មផ្ទៃក្នុងទៅកាន់គណៈកម្មការសវនកម្ម។
- ធានាទូវការឆ្លើយតប និងចំណាត់ការពីគណៈគ្រប់គ្រង ចំពោះលទ្ធផលនៃការធ្វើសវនកម្ម និងការអនុវត្តអនុសាសន៍នានា ដែលផ្តល់ដោយសវនករផ្ទៃក្នុង ទៅតាមពេលវេលាដែលបានព្រមព្រៀង។ អនុវត្តការងារផ្សេងទៀតតាមការចាត់តាំងដោយ គណៈកម្មការសវនកម្ម។
- ជួយគណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាលក្នុងការបំពេញនូវទំនួលខុសត្រូវ ទៅលើការអនុវត្តត្រឹមត្រូវនៃគោលនយោបាយគណនេយ្យ របាយការណ៍ភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង។

# គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ

គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ ត្រូវបានបង្កើតឡើង នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ គណៈកម្មការនេះ មានតួនាទីភារកិច្ចជាចម្បងក្នុងការធានាថា គោលនយោបាយអត្ថប្រយោជន៍របស់បុគ្គលិកមានសង្គតិភាពនឹងគោលដៅរយៈពេលវែង គុណតម្លៃស្នូលរបស់ធនាគារ អត្ថប្រយោជន៍ត្រូវមានភាពប្រហាក់ប្រហែលទៅគ្រឹះស្ថានហិរញ្ញវត្ថុនានា និងកត្តាផ្សេងៗទៀតដែលបម្រើឱ្យតម្រូវការហិរញ្ញវត្ថុ និងតម្រូវការពាណិជ្ជកម្មរបស់ធនាគារ។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងស្របតាមប្រកាសធនាគារជាតិនៃកម្ពុជាលេខធ៧-០៨-២១១ប្រ.កស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ បច្ចុប្បន្នគណៈកម្មការនេះ មានសមាជិកចំនួន ៣ (បី)រូប និងប្រធានចំនួន ១ (មួយ)រូប ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តម សុន សេងហួត | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម ចាន់ សុខទី | សមាជិក |
| ៤ | លោកស្រី ឈន ដាលិះ | សមាជិកា |

គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ អនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យលើគ្រប់ទិដ្ឋភាពនៃតម្លៃការទាំងអស់ មិនកំណត់តែលើប្រាក់កម្រៃរបស់អភិបាលដែលមានដូចជា៖ ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ, ការចំណាយថ្លៃប្រឹក្សាយោបល់ (ប្រសិនបើមាន), និងអត្ថប្រយោជន៍ផ្សេងៗ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលអំពីតម្លៃការរបស់អភិបាលធនាគារ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវគោលដៅប្រចាំឆ្នាំ និងផែនការអត្ថប្រយោជន៍ (រួមទាំងប្រាក់រង្វាន់ និងផែនការផ្សេងទៀតដែលបង្កើតឡើងដើម្បីជំរុញដល់ការបង្កើនតម្លៃរួមរយៈពេលវែង) សម្រាប់គណៈគ្រប់គ្រងធនាគារ នាយក/នាយិកាសវនកម្មផ្ទៃក្នុង និងមន្ត្រីប្រតិបត្តិតាម សម្រាប់ឆ្នាំបន្ទាប់។
- ពិនិត្យឡើងវិញនូវប្រាក់ឧបត្ថម្ភ និងទម្រង់នៃអត្ថប្រយោជន៍ផ្សេងៗដល់គណៈគ្រប់គ្រង និងប្រធានផ្នែកសំខាន់ៗរបស់ធនាគារ ដើម្បីធានាភាពសមស្របគ្នាទៅនឹងការទទួលខុសត្រូវ និងហានិភ័យពាក់ព័ន្ធនឹងសមាជិកភាពប្រកបដោយប្រសិទ្ធភាពរបស់គណៈគ្រប់គ្រង។
- ពិនិត្យឡើងវិញ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មការ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។
- ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធយ៉ាងហោចណាស់ ម្តងក្នុងមួយឆ្នាំ សម្រាប់ស្នើសុំអនុម័តពីក្រុមប្រឹក្សាភិបាល។

## សមិទ្ធផលដែលគណៈកម្មការតែងតាំង និងផ្តល់តម្លៃការសម្រេចបានក្នុងឆ្នាំ២០២៤៖

- ពិនិត្យ និងផ្តល់ការឯកភាពជាគោលការណ៍ លើលទ្ធផលវាយតម្លៃសូចនាករការងាររបស់បុគ្គលិកប្រចាំឆ្នាំ
- ពទិត្យ និងផ្តល់ការឯកភាពជាគោលការណ៍ លើការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំ២០២៥ និងកំណត់អត្រាផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំ២០២៤ ដល់បុគ្គលិកធនាគារ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងសម្រេចផ្តល់ការឯកភាពលើការកំណត់សូចនាករវាយតម្លៃការងារ ប្រចាំឆ្នាំ២០២៤ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងសម្រេចផ្តល់ការឯកភាពលើការកំណត់លក្ខខណ្ឌការងារ របស់គណៈកម្មការប្រតិបត្តិ និងតំណាងបុគ្គលិកមុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងផ្តល់យោបល់លើការកំណត់លក្ខខណ្ឌការងារ របស់នាយកដ្ឋាន និងការិយាល័យ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងសម្រេចផ្តល់ការឯកភាពលើការកែសម្រួលក្រមប្រតិបត្តិ មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងសម្រេចផ្តល់ការឯកភាពលើសំណើសុំជ្រើសរើសបុគ្គលិកថ្មីបន្ថែមរបស់នាយកដ្ឋាន/ការិយាល័យ និងសាខាសម្រាប់ឆ្នាំ២០២៤
- ពិនិត្យ និងសម្រេចផ្តល់ការឯកភាពគោលនយោបាយផែនការបន្តនិរន្តភាពនៃការគ្រប់គ្រង មុនដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត

# របាយការណ៍ ហិរញ្ញវត្ថុ





# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ហៅកាត់ថា “ធនាគារ”) សូមដាក់បង្ហាញនូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## | សកម្មភាពអាជីវកម្មចម្បង

ធនាគារត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាធនាគារគ្រប់គ្រងដោយរដ្ឋ ដែលរៀបចំឡើងក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈដែលមានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ Co. 0009M/២០២០ ដែលបានចេញផ្សាយដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ ធនាគារស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។

ធនាគារទទួលបានអាជ្ញាបណ្ណរបស់ខ្លួនពីធនាគារជាតិនៃកម្ពុជា (“NBC”) នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងស្ថិតនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវអូស៊ីអាយស៊ី ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## | លទ្ធផលនៃប្រតិបត្តិការ និងភាគលាភ

លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ខែធ្នូឆ្នាំ២០២៤ និងស្ថានភាពនៃអាជីវកម្មរបស់ធនាគារនាកាលបរិច្ឆេទនោះ គឺត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយ។

ពុំមានភាគលាភត្រូវបានដាក់ស្នើ បានប្រកាស ឬបានទូទាត់ដោយធនាគារក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

## | ការខាតបង់ឥណទានដែលបានរំពឹងទុកលើឥណទាន និងបុរេប្រទាន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីឈានដល់ការអះអាងថាទីតិវិធីដែលពាក់ព័ន្ធនឹងការលុបឥណទានអាក្រក់ចេញពីបញ្ជី ឬការទទួលស្គាល់នៃសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថារាល់ឥណទានអាក្រក់ដែលបានទទួលស្គាល់ ត្រូវបានលុបចេញពីបញ្ជី និងបានធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះការខាតបង់ឥណទានដែលបានរំពឹងទុកលើឥណទាន និងបុរេប្រទានទាំងនោះ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងច្បាស់លាស់បំផុតរបស់យើងខ្ញុំ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានការណ៍ណាមួយ ដែលបណ្តាលឱ្យសមតុល្យនៃឥណទានអាក្រក់ដែលបានលុបចេញ ឬសមតុល្យនៃសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមិនមានភាពគ្រប់គ្រាន់ចំពោះវិសាលភាពជាសារវន្តណាមួយឡើយ។

## | ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីធានាថាទ្រព្យសកម្មទាំងឡាយណា ដែលទំនងជាមិនអាចទទួលស្គាល់បានក្នុងប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារតាមតម្លៃដូចដែលបានបង្ហាញក្នុងកំណត់ត្រាគណនេយ្យរបស់ធនាគារត្រូវបានកាត់បន្ថយឱ្យស្មើនឹងសមតុល្យដែលត្រូវបានរំពឹងទុកថាអាចទទួលស្គាល់បាន។

នាកាលបរិច្ឆេទនៃរបាយកាណ៍នេះ និងផ្អែកលើការយល់ដឹងច្បាស់លាស់បំផុត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានការណ៍ណាមួយដែលនឹងបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវជាសារវន្តណាមួយឡើយ។

## | វិធីសាស្ត្រវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## | បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺ៖

(ក) ពុំមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ដែលដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ លើកលែងតែបានលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(ខ) ពុំមានបំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះធនាគារចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងបញ្ចប់ការិយបរិច្ឆេទដែលនឹងមាន ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្តាលឱ្យសមតុល្យណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុថាមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងចុងការិយបរិច្ឆេទនេះ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបច្ចុប្បន្នដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលកាន់តំណែងក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចជា៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង/(ការលាឈប់) |
|---|---|---|
| ឯកឧត្តមបណ្ឌិត ផាន់ ផល្លា | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ |
| ឯកឧត្តម ទេព ភិរ្យៅវិទ្ធ | សមាជិក | ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ |
| ឯកឧត្តម សុន សេងហួត | សមាជិក | ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ |
| ឯកឧត្តម ចាន់ សុខទី | សមាជិក | ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ |
| លោកស្រី ឈន ដាលិះ | សមាជិកា | ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ |
| លោក ជា សុភ័ក្ត | អគ្គនាយកស្តីទី និងសមាជិក | ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ |
| បណ្ឌិត លឹម អូន | អគ្គនាយក និងសមាជិក | ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ (បានលាឈប់) |
| លោក នៀវ សុគន្ធ | នាយកប្រតិបត្តិប្រតិបត្តិការ និងសមាជិក | ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៤ (បានលាឈប់) |

## | សវនករ

របាយការណ៍ហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនស្នងការគណនេយ្យ ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត។

## | ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ភាគកម្មណាមួយក្នុងគណនីមូលធនរបស់ធនាគារឡើយ។ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងផ្តល់លទ្ធភាពដល់សមាជិកឱ្យទទួលបានភាគកម្មនៅក្នុងធនាគារ ឬសកម្មភាពសាជីវកម្មផ្សេងៗទៀតនោះទេ។

## | អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍តាមរយៈមធ្យោបាយទិញយកភាគហ៊ុន ឬបណ្ណបំណុលរបស់ធនាគារ ឬសកម្មភាពសាជីវកម្មផ្សេងៗទៀតនោះទេ។

ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានអភិបាលរបស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធជាមួយនឹងធនាគារដែលមានអភិបាលនោះជាសមាជិកឬជាមួយក្រុមហ៊ុនដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែមានការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## | ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលបង្ហាញនូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ គណៈគ្រប់គ្រងតម្រូវឱ្យ៖

- អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប បានគាំទ្រដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព
- អនុលោមតាមតម្រូវការស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាដែលអនុម័តដោយនិយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជា ដោយផ្អែកលើស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ ឬប្រសិនបើមានការប្រាសចាកណាមួយពីតម្រូវការទាំងនោះ ក្នុងការបង្ហាញនូវភាពទិដ្ឋភាពពិតនិងត្រឹមត្រូវ ត្រូវប្រាកដថាការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ

- រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

- វាយតម្លៃលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាព ការលាតត្រដាង ប្រសិនបើមានបញ្ហាដែលទាក់ទងនឹងការបន្តនិរន្តរភាព និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏មិនមានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ និង

- ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថារាល់ការសម្រេចចិត្ត និង/ឬសេចក្តីណែនាំត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញនូវការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាល សូមបញ្ជាក់ថាធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំ និងត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

## | សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមមកជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានរៀបចំឡើងយ៉ាងសមស្រប និងផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ចុះហត្ថលេខាជំនួសឱ្យក្រុមប្រឹក្សាភិបាល៖

**ឯកឧត្តមបណ្ឌិត ផាន់ ផល្លា**
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាភិបាល

**លោក ជា សុភ័ក្ត**
អគ្គនាយកស្តីទី និងសមាជិក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគហ៊ុនិករបស់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក

## | មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ហៅកាត់ថា “ធនាគារ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងគោលនយោបាយគណនេយ្យជាសារវន្ត និងសេចក្តីពន្យល់ព័ត៌មានផ្សេងៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលអនុម័តដោយនិយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជាដោយផ្អែកលើស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ ព្រមទាំងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## | មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដាទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីធនាគារដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដាវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## | ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវទាំងស្រុងទៅលើការរៀបចំព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរបាយការណ៍សវនកររបស់យើងខ្ញុំឡើយ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថាបានរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនផ្តល់សេចក្តីសន្និដ្ឋានក្នុងទម្រង់នៃការធានាបែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើ ផ្អែកតាមការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហានោះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## | ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុពុំឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពធនាគារក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំលាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

# | ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផលទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូលដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈដ្ឋាគុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។

- វាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ និងផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពក្នុងការបន្តនិរន្តរភាពរបស់ធនាគារ។ ប្រសិនបើ យើងខ្ញុំសន្និដ្ឋានថាភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យធនាគារមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពសមស្របដែរឬទេ។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយបុគ្គលមានអភិបាលកិច្ចទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

Grant Thornton

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣ | ១.៩៤៧.១៦៩ | ៧.៨៣៧.៣៥៥ | ១.៩៩៨.៦៣៤ | ៨.១៦៤.៤២០ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៤ | ១២.១៧១.៤៧០ | ៤៨.៩៩០.១៦៧ | ១០.២៤៥.៨៣៣ | ៤១.៨៥៤.២២៨ |
| សមតុល្យនៅធនាគារផ្សេងៗ | ៥ | ១៥០.៣៦៣.៧៥៤ | ៦០៥.២១៤.១១០ | ៩១.០៨២.៧៩៣ | ៣៧២.០៧៣.២០៩ |
| ឥណទាន និងបុរេប្រទានផ្តល់ជូនអតិថិជន – សុទ្ធ | ៦ | ២១១.២០០.១៤១ | ៨៥០.០៨០.៥៦៨ | ២១១.៩៣៣.៨៥៣ | ៨៦៥.៧៤៩.៧៩០ |
| ទ្រព្យសកម្មអរូបី | ៨ | ៣០៨.៨២១ | ១.២៤៣.០០៥ | ៦១៤.៤១៩ | ២.៥០៩.៩០២ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ១.៥៣៤.០៤៥ | ៦.១៧៤.៥៣១ | ២.១៤៥.៥១១ | ៨.៧៦៤.៤១២ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | ១០ | ១.៦៦១.៩៣៥ | ៦.៦៨៩.២៨៨ | ២.០៣៤.៦០១ | ៨.៣១១.៣៤៥ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | ១១ | ៤៣៩.១៥៥ | ១.៧៦៧.៥៩៩ | ៣៣៨.២៧២ | ១.៣៨១.៨៤១ |
| ទ្រព្យសកម្មពន្ធពន្យារ | ១២ (IV) | ៤៤៥.៦៤០ | ១.៧៩៣.៧០១ | ៨៣៦.៩១៧ | ៣.៤១៨.៨០៥ |
| ទ្រព្យសកម្មផ្សេងៗ | ៧ | ៣០៨.២០០ | ១.២៤០.៥០៥ | ៣៨៦.៦៧៧ | ១.៥៧៩.៥៧៥ |
| **ទ្រព្យសកម្មសរុប** | | **៣៨០.៣៨០.៣៣០** | **១.៥៣១.០៣០.៨២៩** | **៣២១.៦១៧.៥១០** | **១.៣១៣.៨០៧.៥២៧** |
| មូលធន និងបំណុល | | | | | |
| មូលធន | | | | | |
| ដើមទុន | ១៧ | ២០០.០០០.០០០ | ៨០០.០០០.០០០ | ២០០.០០០.០០០ | ៨០០.០០០.០០០ |
| វិភាគទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៨ | ១.២៤៦.៨៨២ | ៤.៩៨៧.៥២៨ | ១.២៤៦.៨៨២ | ៤.៩៨៧.៥២៨ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៩ | ៨.១៦០.៣៦២ | ៣២.៨៤៥.៤៥៧ | ១.២៥៩.៥៨៤ | ៥.១៤៥.៤០១ |
| ខាតបង្គរ | | (៩.៧៤៨.៦៦៦) | (៣៩.៣១៨.៨៣៨) | (៤.២១៣.៣៤៤) | (១២.១៧៧.៥៥៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | | - | ៥.១១១.៦២៩ | - | ១៧.០៧២.០២៧ |
| **មូលធនសរុប** | | **១៩៩.៦៥៨.៥៧៨** | **៨០៣,៦២៥,៧៧៦** | **១៩៨.២៩៣.១២២** | **៨១០.០២៧.៤០៣** |
| បំណុល | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១៣ | ៣០.៦៦២ | ១២៣.៤១៥ | ៥២.៨៥៥ | ២១៥.៩១៣ |
| ប្រាក់បញ្ញើពីអតិថិជន | ១៤ | ៤.៧៧៥.៩៦២ | ១៩.២២៣.២៤៧ | ៣.៩៦៤.៨៦០ | ១៦.១៩៦.៤៥៣ |
| ប្រាក់កម្ចី | ១៥ | ១៧៣.៥៧៧.៩៧៧ | ៦៩៨.៦៥១.៣៥៧ | ១១៦.៥១១.៥៧៣ | ៤៧៥.៩៤៩.៧៧៦ |
| បំណុលពន្ធលើប្រាក់ចំណូល | ១២ (I) | ១២.៤៩៦ | ៥០.២៩៧ | ១១.៥២១ | ៤៧.០៦៣ |
| បំណុលភតិសន្យា | ១០ | ១.៧២៥.៣៣០ | ៦.៩៤៤.៤៥៣ | ២.១០០.០៤១ | ៨.៥៧៨.៦៦៧ |
| បំណុលផ្សេងៗ | ១៦ | ៥៩៩.៣២៥ | ២.៤១២.២៨៤ | ៦៨៣.៥៣៨ | ២.៧៩២.២៥២ |
| បំណុលសរុប | | **១៨០.៧២១.៧៥២** | **៧២៧.៤០៥.០៥៣** | **១២៣.៣២៤.៣៨៨** | **៥០៣.៧៨០.១២៤** |
| មូលធន និងបំណុលសរុប | | **៣៨០.៣៨០.៣៣០** | **១.៥៣១.០៣០.៨២៩** | **៣១២.៦១៧.៥១០** | **១.៣១៣.៨០៧.៥២៧** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍ចំណូលលម្អិត

## សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ចំណូលការប្រាក់ | ២០ | ១៣.៥៣២.៤៤៨ | ៥៥.០៩០.៥៩៦ | ១០.៧៨០.៤៨៣ | ៤៤.៣០៧.៧៨៥ |
| ចំណាយការប្រាក់ | ២០ | (២.៧៦០.៣៨៥) | (១១.២៣៧.៥២៧) | (១.៧១១.៤០៣) | (៧.០៣៣.៨៦៦) |
| **ចំណូលការប្រាក់សុទ្ធ** | | ១០.៧៧២.០៦៣ | ៤៣.៨៥៣.០៦៩ | ៩.០៦៩.០៨០ | ៣៧.២៧៣.៩១៩ |
| កម្រៃសេវា និងកម្រៃជើងសាសុទ្ធ | ២១ | ៤០៦.៦០៩ | ១.៦៥៥.៣០៥ | ២០៣.៥៩៤ | ៨៣៦.៧៧១ |
| (ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | | (៣០៩.៩៤៣) | (១.២៦១.៧៧៨) | ២១៥.៥៣៧ | ៨៨៥.៨៥៧ |
| **ចំណូលប្រតិបត្តិការសរុប** | | **១០.៨៦៨.៧២៩** | **៤៤.២៤៦.៥៩៦** | **៩.៤៨៨.២១១** | ៣៨.៩៩៦.៥៤៧ |
| សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបាន រំពឹងទុក | ៦ | (១.៦៣៩.៣២៤) | (៦.៦៧៣.៦៨៨) | (៣.៥១៧.២៥៨) | (១៤.៤៥៥.៩៣០) |
| ចំណាយលើបុគ្គលិក | ២២ | (៤.១៥៤.៨១៤) | (១៦.៩១៤.២៤៨) | (៣.៥៤៩.៥៨៧) | (១៤.៥៨៨.៨០៣) |
| រំលស់លើទ្រព្យសកម្មរូបី និងអរូបី | ២៣ | (១.៤៣៧.៨០១) | (៥.៨៥៣.២៨៨) | (១.២៤៧.៩៥០) | (៥.១២៩.០៧៥) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៤ | (១.៧៤០.០១៣) | (៧.០៨៣.៥៩៣) | (១.៣៦៦.៣១៩) | (៥.៦១៥.៥៧១) |
| **ចំណេញ/(ខាត) មុនបង់ពន្ធលើប្រាក់ចំណូល** | | ១.៨៩៦.៧៧៧ | ៧.៧២១.៧៧៩ | (១៩២.៩០៣) | (៧៩២.៨៣២) |
| ចំណាយពន្ធលើប្រាក់ចំណូល | ១២ (ii) | (៥៣១.៣២១) | (២.១៦៣.០០៨) | (៧៩.៤៨៨) | (៣២៦.៦៩៦) |
| **ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ** | | ១.៣៦៥.៤៥៦ | ៥.៥៥៨.៧៧១ | (២៧២.៣៩១) | (១.១១៩.៥២៨) |
| **ខាតលម្អិតផ្សេងៗ)** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១១.៩៦០.៣៩៨) | - | (៦.៣៤៧.២៨៦) |
| **ចំណូល/(ខាត)លម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **១.៣៦៥.៤៥៦** | **(៦.៤០១.៦២៧)** | **(២៧២.៣៩១)** | **(៧.៤៦៦.៨១៤)** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | ដើមទុន | វិភាគទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខាតបង្គរ | ទុនបម្រុងតាមបទប្បញ្ញត្តិ | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | **មូលធនសរុប** | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ | ២០០.០០០.០០០ | ១.២៤៦.៨៨២ | (៤.២១៣.៣៨៤) | ១.២៥៩.៥៨៤ | ១៧.០៧២.០២៧ | ១៩៨.២៩៣.១២២ | ៨១០.០២៧.៤០៣ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | ១.៣៦៥.៤៥៦ | - | - | ១.៣៦៥.៤៥៦ | ៥.៥៥៨.៧៧១ |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (៦.៩០០.៧៧៨) | ៦.៩០០.៧៧៨ | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (១១.៩៦០.៣៩៨) | - | (១១.៩៦០.៣៩៨) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | **២០០.០០០.០០០** | **១.២៤៦.៨៨២** | **(៩.៧៤៨.៦៦៦)** | **៨.១៦០.៣៦២** | **៥.១១១.៦២៩** | **១៩៩.៦៥៨.៥៧៨** | **៨០៣.៦២៥.៧៧៦** |
| | | | | | | | |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ២០០.០០០.០០០ | ១.២៤៦.៨៨២ | (២.៦៨១.៣៦៩) | - | ២៣.៤១៩.៣១៣ | ១៩៨.៥៦៥.៥១៣ | ៨១៧.៤៩៤.២១៧ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | (២៧២.៣៩១) | - | - | (២៧២.៣៩១) | (១.១១៩.៥២៨) |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (១.២៥៩.៥៨៤) | ១.២៥៩.៥៨៤ | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (៦.៣៤៧.២៨៦) | - | (៦.៣៤៧.២៨៦) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ២០០.០០០.០០០ | ១.២៤៦.៨៨២ | (៤.២១៣.៣៨៤) | ១.២៥៩.៥៨៤ | ១៧.០៧២.០២៧ | ១៩៨.២៩៣.១២២ | ៨១០.០២៧.៤០៣ |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណូល | | ១.៨៩៦.៧៧៧ | ៧.៧២១.៧៧៩ | (១៩២.៩០៣) | (៧៩២.៨៣២) |
| **និយ័តកម្មសម្រាប់៖** | | | | | |
| សំវិធានធនសម្រាប់ការខាតបង់ឥណទាន ដែលបានរំពឹងទុក | ៦ | ១.៦៣៩. ៣២៤ | ៦.៦៧៣.៦៨៨ | ៣.៥១៧.២៥៨ | ១៤.៤៥៥.៩៣០ |
| ចំណាយការប្រាក់លើប្រាក់កម្ចី | ១៥ | ២.៦០២.៨៧០ | ១០.៥៩៦.២៨៤ | ១.៥៤៧.៥៣៩ | ៦.៣៦០.៣៨៥ |
| រំលស់លើទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | ២៣ | ១.៤៣៧.៨០១ | ៥.៨៥៣.២៨៨ | ១.២៤៧.៩៥០ | ៥.១២៩.០៧៥ |
| ការវាយតម្លៃរូបិយប័ណ្ណឡើងវិញលើប្រាក់កម្ចី | ១៥ | ១.១៩៨.៩៤៨ | ៤.៨៨០.៩១៧ | ៥៧៩.៨០៩ | ២.៣៨៣.០១៥ |
| ចំណេញលើការប្តូររូបិយប័ណ្ណបរទេសដែល មិនបានទទួលស្គាល់ | | ៣១៤.៤៤៧ | ១.២៨០.១១៤ | ៣២១.៤៤៩ | ១.៣២១.១៥៥ |
| ការលុបចោលកម្មវិធីកុំព្យូទ័រកំពុងដំណើរការ | ៨ | ៤៦.៨០០ | ១៩០.៥២៣ | - | - |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | ១០ | ៤៤.៥៤៤ | ១៨១.៣៣៩ | ៥២.០២២ | ២១៣.៨១០ |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **៩.១៨១.៥១១** | **៣៧.៣៧៧.៩៣២** | **៧.០៧៣.១២៤** | **២៩.០៧០.៥៣៨** |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| **បម្រែបម្រួលសុទ្ធក្នុង៖** | | | | | |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | | (១០០.៨៨៣) | (៤១០.៦៩៥) | (១៦.៣០៧) | (៦៧.០២២) |
| ឥណទាន និងបុរេប្រទានផ្តល់ជូនអតិថិជន - សុទ្ធ | | (៩០៥.៦១២) | (៣.៦៨៦.៧៤៦) | (៤.៩៥០.១៧៩) | (២០.៣៤៥.២៣៦) |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | (២២.១៩៣) | (៩០.៣៤៨) | ៣.៣៩៤ | ១៣.៩៤៩ |
| ប្រាក់បញ្ញើពីអតិថិជន | | ៨១១.១០២ | ៣.៣០១.៩៩៦ | (៦៩៥.៦៦៤) | (២.៨៥៩.១៧៩) |
| ទ្រព្យសកម្មផ្សេងៗ | | (២៣៧.៩៧០) | (៩៦៨.៧៧៦) | (៥២៩.៨០៧) | (២.១៧៧.៥០៧) |
| បំណុលផ្សេងៗ | | (៨៤.២១៣) | (៣៤២.៨៣១) | (២០១.១៥៣) | (៨២៦.៧៣៩) |
| **សាច់ប្រាក់បានមកពីក្នុងសកម្មភាពប្រតិបត្តិការ** | | ៨.៦៤១.៧៤២ | ៣៥.១៨០.៥៣១ | ៦៨៣.៤០៧ | ២.៨០៨.៨០៣ |
| ពន្ធលើប្រាក់ចំណូលបានបង់ | ១២ (i) | (១៣៩.០៦៩) | (៥៦៦.១៥០) | (៣៣៦.៩៨៤) | (១.៣៨៥.០០៤) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ** | | **៨.៥០២.៦៧៣** | **៣៤.៦១៤.៣៨១** | **៣៤៦.៤២៣** | **១.៤២៣.៧៩៩** |
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ក្នុងប្រាក់បញ្ញើរយៈពេលខ្លី | | (១៦.៩០៩.៤៣២) | (៦៨.៨៣៨.២៩៨) | (៨.១៦៩.៥២៩) | (៣៣.៥៧៦.៧៦៤) |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | (១៧៦.២៥៣) | (៧១៧.៥២៦) | (៩១៥.៩៧៦) | (៣.៧៦៤.៦៦១) |
| ទិញទ្រព្យសកម្មអរូបី | ៨ | (១៦.៧៦៦) | (៦៨.២៥៤) | (១៤៧.៩១៣) | (៦០៧.៩២២) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(១៧.១០២.៤៥១)** | **(៦៩.៦២៤.០៧៨)** | **(៩.២៣៣.៤១៨)** | **(៣៧.៩៤៩.៣៤៧)** |

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) |
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១៥ | ៥៥.៨៥៣.៤៦០ | ២២៧.៣៧៩.៤៣៦ | ៤១.៤៦៧.០៨២ | ១៧០.៤២៩.៧០៧ |
| ការប្រាក់បានបង់លើប្រាក់កម្ចី | ១៥ | (២.៥៨៨.៨៧៤) | (១០.៥៣៩.៣០៦) | (១.០៩៩.១៣១) | (៤.៥១៧.៤២៩) |
| ការទូទាត់បំណុលភតិសន្យា | ១០ | (៤១៩.១០៧) | (១.៧០៦.១៨៥) | (៣៤២.៧៥៥) | (១.៤០៨.៧២៣) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញវត្ថុ** | | **៥២.៨៤៥.៤៧៩** | **២១៥.១៣៣.៩៤៥** | **៤០.០២៥.១៩៦** | **១៦៤.៥០៣.៥៥៥** |
| **ការកើនឡើងសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៤៤.២៤៥.៧០១ | ១៨០.១២៤.២៤៨ | ៣១.១៣៨.២០១ | ១២៧.៩៧៨.០០៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | ៧៥.២៧០.៥៦៨ | ៣០៧.៤៨០.២៧១ | ៤៤.១៣២.៣៦៧ | ១៨១.៦៩២.៩៥៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៦.៥៥១.៥៣៦) | - | (២.១៩០.៦៩១) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ៣ | **១១៩.៥១៦.២៦៩** | **៤៨១.០៥២.៩៨៣** | **៧៥.២៧០.៥៦៨** | **៣០៧.៤៨០.២៧១** |
| ព័ត៌មានបន្ថែមអំពីប្រតិបត្តិការរំហូរសាច់ប្រាក់បានមកពីការប្រាក់៖ | | | | | |
| ការប្រាក់បានទទួល | | ១៣.៣៤៩.១២២ | ៥៤.៣៤៤.២៧៦ | ១០.២៥២.៧១១ | ៤២.១៣៨.៦៤២ |
| ការប្រាក់បានបង់ | | ២.៨៦៥.៧៣១ | ១១.៦៦៦.៣៩១ | ១.៦០៦.៣៨៧ | ៦.៦០២.២៥១ |

លម្អិតពីរបាយការណ៍ហិរញ្ញវត្ថុ
សូមស្កេន

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា

SMALL AND MEDIUM ENTERPRISE BANK OF CAMBODIA

096 811 1118
SME Bank of Cambodia
smebankcambodia.com.kh
info@smebankcambodia.com.kh